ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមិថុនា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១១២

## ក្រោយការបោះឆ្នោត ពលរដ្ឋទីក្រុងចង់បានប្រព័ន្ធល្អ... តែអ្នកនៅជនបទចង់បានយុត្តិធម៌សង្គម និងការអភិវឌ្ឍ



CSC

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ៖ ០២០/១៨ ព.ម.រ.ល.អ/ ០១-មករា-២០១៨

# មេដឹកនាំគណបក្សនយោបាយធំៗសុទ្ធតែប្រើប្រាស់ការឃោសនាតាមបណ្ដាញសង្គម




បណ្ដាញសង្គមបានក្លាយជាប្រចកឃោសនាសកម្មភាពនយោបាយមួយដ៏ចំបងនៅក្នុងយុទ្ធនាការបោះឆ្នោតនៅកម្ពុជាដែលចាប់ផ្ដើមតាំងពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៨មក ហើយនិន្នាការនេះនឹងតែនៅតែបន្តរហូត។ យោងតាមការសង្កេតតាមបណ្ដាញសង្គម គណបក្សធំៗ ដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យជាដើម ។

តាមគណនីហ្វេសបុកផ្លូវការរបស់ខ្លួន សម្ដេចតេជោ ហ៊ុន សែន បានថ្លែងសារជាបន្តបន្ទាប់ តាមបណ្ដាញសង្គមគឺមានដូចជា "នៅមុននេះ ភ្លៀងមួយមេធំបានធ្លាក់យ៉ាងខ្លាំងនៅទីក្រុងភ្នំពេញ។ ដើម្បីសុវត្ថិភាព សូមបងប្អូនកុំបើកបរលឿនអាចជ្រុលចង្កូត និងអាចជះទឹកសាចទៅលើបងប្អូនអ្នកធ្វើដំណើរដោយម៉ូតូឬម៉ែកកង់បី។ នេះជាថ្ងៃទី២ (៨កក្កដា) ហើយនៃថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។ សុំអរគុណសមាជិកសមាជិការ និងកូនក្មួយយុវជនយុវតីនៃគណបក្សប្រជាជនទូទាំងប្រទេសដែលចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនេះ។ ជាការពិត គឺបងប្អូនជនរួមជាតិបានដឹងច្បាស់ហើយថា កម្ពុជាសុខសប្បាយ និងរីកចម្រើនមកទល់ថ្ងៃនេះ គឺដោយសារបាតដៃគណបក្សប្រជាជនតែមួយគត់។ អរគុណបងប្អូនជនរួមជាតិដែលមានជំនឿ និងគាំទ្រឥតងាករេលើការដឹកនាំរបស់ខ្ញុំ។ ជម្រើសដ៏ល្អបំផុតនោះ គឺសូមបងប្អូនបន្តបោះឆ្នោតឲ្យ "គណបក្សប្រជាជនកម្ពុជា" លេខរៀងទី២០ នៅថ្ងៃបោះឆ្នោតទី ២៩ កក្កដា ២០១៨ ខាងមុខនេះ"។

ក្រៅពីសារនេះ សម្ដេចតេជោ ហ៊ុន សែន ដែលជាប្រធានគណបក្សប្រជាជនកម្ពុជា ក៏បានចែករំលែកនូវសារទៀតថា "គណបក្សប្រជាជនតែ១គត់ ដែលបានរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ និងបានរួមសុខរួមទុក្ខជាមួយបងប្អូនជនរួមជាតិតាំងពីកម្ពុជានៅក្រោមគំនរផេះផង់រហូតដល់កម្ពុជាមានអ្វីៗគ្រប់យ៉ាងដូចសព្វថ្ងៃនេះ។ គណបក្សប្រជាជន ប្ដេជ្ញាការពារសន្តិភាព និងបន្តអភិវឌ្ឍន៍ប្រទេសជាតិឲ្យកាន់តែរីកចម្រើនរុងរឿងសំបូរសប្បាយ។ គណបក្សប្រជាជនឈ្នះ គឺកម្ពុជាទាំងមូលឈ្នះ!។ អរគុណ និងជូនពរបងប្អូនកូនក្មួយយុវជន សមាជិកសមាជិការគណបក្សប្រជាជន នៅស្រុកពាមរក៍ ខេត្តព្រៃវែងទាំងអស់គ្នា!" ។ សម្ដេចតេជោ ហ៊ុន សែន ត្រូវបានរំពឹងថា នឹងបន្តចែករំលែកសារជាច្រើនទៀត បើទោះបីជាវត្តមានរបស់លោកហាក់ស្ងប់ស្ងាត់កាលពីមុនយុទ្ធនាក៏ដោយ ។

ក្រៅពីគណបក្សប្រជាជនកម្ពុជា លោក យ៉ង សាំងកុមារ បេក្ខជននាយករដ្ឋមន្ត្រីរបស់គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ក៏ជាអ្នកនយោបាយមួយរូបដែលប្រើប្រាស់បណ្ដាញព័ត៌មានសង្គមផងដែរ។ លោក យ៉ង សាំងកុមារ បានចែករំលែកនូវសារមួយទៀតថា "លើកស្ទួយគ្រួសារកសិករឱ្យមានជីវភាពធូរធារជំរុញឱ្យជនបទរីកចម្រើន នោះសេដ្ឋកិច្ចជាតិរឹងមាំ! លេខ៧គណបក្សប្រជាធិបតេយ្យមូលដ្ឋាន"។ លោក យ៉ង សាំងកុមារក៏បានចែករំលែកនូវសារមួយទៀតថា "អ្នកគាំទ្រថា ខ្ញុំជានាយករដ្ឋមន្ត្រីបន្លែធម្មជាតិ។ បន្លែធម្មជាតិខ្មែរ និងបន្លែគីមីបរទេសយកមួយណា? ការនាំកសិផលគីមីចូលកំពុងប៉ះពាល់ ដល់សុខភាពប្រជាពលរដ្ឋនិងសេដ្ឋកិច្ចជាតិ។ ទិញបន្លែគេ ហើយពេលឈឺទៅព្យាបាលស្រុកគេទៀត។ យើងត្រូវដូរការដឹកនាំប្រទេសរបៀបនេះចេញ ជាពិសេសយើងត្រូវកែទម្រង់វិស័យកសិកម្ម សុវត្ថិភាពចំណីអាហារនិងសុខាភិបាល។ GDP លេខ៧គណបក្សប្រជាធិបតេយ្យមូលដ្ឋាន"។ គណបក្សប្រជាធិបតេយ្យមូលដ្ឋានមានលេខរៀងទី៧ នៅលើសន្លឹកឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អណត្តិទី៦នេះ។

សម្រាប់លោក ខឹម វាសនា ប្រធានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ក៏សកម្មនៅក្នុងហ្វេសបុកផងដែរតាំងពីដើមរៀងមក។ លោកបានព្យាយាមចែករំលែកសកម្មភាពគណបក្ស ដោយប្រើហ្វេសបុកដើម្បីប្រាប់អ្នកគាំទ្ររបស់គណបក្សលោកនូវសកម្មភាព នៅក្នុងយុទ្ធនាប៉ុន្មានថ្ងៃនេះ ។គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមានលេខរៀងទី១០ នៅលើសន្លឹកឆ្នោតជ្រើស តាំងតំណាងរាស្ត្រអណត្តិទី៦នេះ៕

*ដោយអរិយបុត្រ*

# ប្រពលវប្បកម្មដំណាំស្រូវទប់ទល់នឹងការប្រែប្រួលអាកាសធាតុ

ការដាំស្រូវតាមបែបប្រពលវប្បកម្ម គឺវាធន់នឹងការប្រែប្រួលអាកាសធាតុ ជាជាងការដាំស្រូវ តាមបែបបុរាណ ដោយហេតុថា សំខាន់វាមានចន្លោះទូលាយសម្រាប់គុម្ពនីមួយៗ នាំឲ្យស្រូវមានឫសមាំ។ ដូច្នេះ ស្រូវអាចរស់នៅបានយូរពេលខ្វះទឹក ឬរាំងស្ងួត។ ស្រូវមិនអណ្តែតតាមទឹកពេលទឹកជំនន់ ឬមិនដួលរលំពេលខ្យល់បក់បោកខ្លាំង។

ទាំងនេះ គឺជាបច្ចេកទេសមួយចំនួនដែលប្រជាកសិករអាចធ្វើ នៅពេលពួកគាត់ចង់ពង្រីកបច្ចេកទេសដាំស្រូវឲ្យបានទិន្នផលកាន់តែប្រសើរ។

ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ មានបច្ចេកទេសសំខាន់ៗ ជាសង្ខេប ទាំង១២ នោះគឺ ទី១. ប្រើជីធម្មជាតិដើម្បីឲ្យដីផុសល្អ។ ទី២. ប្រើពូជល្អ និងរើសយកតែគ្រាប់ពេញល្អសម្រាប់យកទៅសាប។ ទី៣. ធ្វើថ្នាលសំណាបគោក ហើយសាបស្តើង ដើម្បីឲ្យសំណាបថ្លោសល្អ។ ទី៤. ដកថ្នមៗ យកតែសំណាបណាថ្លោសៗ រួចយកទៅស្ទូងភ្លាមៗ។ ទី៥.ស្ទូងសំណាបអាយុខ្ចី យកល្អអាយុតិចជាង ១៥ថ្ងៃ។ ទី៦. ស្ទូងចាប់ស្តើង យកល្អស្ទូងតែមួយដើមក្នុងមួយគុម្ព។ ទី៧. ស្ទូងថ្នមៗ រាក់ៗ និងកុំឲ្យបត់ឫសដូចផ្លែសន្ទូច។ ទី៨. ស្ទូងជាជួរដោយចម្ងាយពីគុម្ពមួយទៅគុម្ពមួយស្មើៗគ្នា។ ទី៩. ស្ទូងឲ្យរង្វើលពីគ្នាដោយទុកចន្លោះពី ២.៥ ទៅ ៤សម។ ទី១០. ជៀសវាងកុំឲ្យមានទឹកដក់ច្រើននៅក្នុងស្រែ ពេលស្រូវកំពុងលូតលាស់។ ទី១១. ដកស្មៅ និងបំផុសដីឲ្យបានពី ២ ទៅ ៤ដង ដើម្បីឲ្យខ្យល់ចេញចូលល្អ និងចុងក្រោយទី១២. ធ្វើដីឲ្យបានរាបស្មើ និងមានប្រព័ន្ធសម្រាប់បញ្ចេញបញ្ចូលទឹក។

ខាងក្រោមនេះជាបច្ចេកទេសលំអិតក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។

ជាដំបូងកសិករត្រូវស្វែងរកពូជផ្តល់ទិន្នផលខ្ពស់។ គ្រាប់ពូជសុទ្ធដែលមានគុណភាព គឺដំណុះគ្រាប់ចាប់ពី ៨៥% ឡើងទៅ។ រយៈពេលលូតលាស់ (ស្រូវស្រាល ឬស្រូវកណ្តាល)។ ភាពធន់ទ្រាំនឹងការរាំងស្ងួត សត្វល្អិតចង្រៃ និងជំងឺ។ គុណភាពគ្រាប់អង្ករ និងរសជាតិ ដែលត្រូវទីផ្សារ។

បន្ទាប់មកប្រសិនបើជាកសិករសង្កេតឃើញគ្រាប់ពូជមានដំណុះទាប ដោយសារមានលាយសំដីច្រើន។ កសិករអាចធ្វើការជ្រើសរើសគ្រាប់ដែលល្អសម្រាប់យកទៅសាបដោយគ្រាន់តែចាក់គ្រាប់ពូជចូលទៅក្នុងធុង រួចចាក់ទឹកចូលឲ្យជិតពេញធុងកូរឲ្យសព្វ រួចមកស្រង់យកគ្រាប់ដែលអណ្តែតលើផ្ទៃទឹកចេញ។ ចំណែកគ្រាប់លិចក្នុងទឹក ចាក់ទុកមួយកន្លែង រួចបន្តធ្វើរបៀបនេះរហូតដល់អស់គ្រាប់ពូជ ដែលត្រូវយកទៅសាប។

កសិករត្រូវជ្រើសរើស និងរៀបចំកន្លែងសម្រាប់សាប។ ការធ្វើដូច្នេះគឺដើម្បីងាយស្រួលក្នុងការបញ្ចេញបញ្ចូលទឹក ពេលរាំងស្ងួត ឬទឹកជំនន់។ ងាយស្រួលការពារសត្វពាហនៈ និងបក្សី។ ដីថ្នាលត្រូវមានជីជាតិល្អ ដើម្បីធ្វើឲ្យដងដើមមានសុខភាពល្អ អាចធន់ទ្រាំនឹងគ្រោះរាំងស្ងួតរយៈពេលខ្លី។ កន្លែងសាបត្រូវស្ថិតនៅឆ្ងាយពីម្លប់រុក្ខជាតិ។

កសិកររៀបចំថ្នាលដោយបំផុសដីឲ្យបានម៉ត់ ហាលថ្ងៃឲ្យបានពី៧ថ្ងៃ ទៅ ១០ថ្ងៃសម្អាតស្មៅ និងពង្រាបដីឲ្យបានរាបស្មើ។ កសិករប្រើជីធម្មជាតិជីកំប៉ុស្ត ដែលពុកផុយល្អប្រមាណ ២០០គីឡូក្រាមសម្រាប់ថ្នាល ១០០ម៉ែត្រការ៉េ។ ជីធម្មជាតិប្រើនៅពេលទ្រាប់បាតនៅពេលរៀបចំដី និងពង្រាយឲ្យបានសព្វ។ កសិកររៀបចំថ្នាលសំណាបគោក ដែលមានទីតាំងនៅក្បែរប្រភពទឹក មានពន្លឺថ្ងៃគ្រប់គ្រាន់ និងងាយស្រួលក្នុងការការពារថ្នាល។ កសិករអាចលើកជារងដែលមានទទឹងពី ១.២ម៉ែត្រទៅ១.៥ម៉ែត្រនិងបណ្តោយអាស្រ័យទៅតាមស្ថានភាពដីជាក់ស្តែង។

មុននឹងធ្វើស្រែ កសិករត្រូវភ្ជួររាស់ដីស្រែឲ្យបានច្រើនសា និងមានជម្រៅយ៉ាងតិច ១៥សម ហើយរាស់ពង្រាបឲ្យបានស្មើល្អ ដើម្បីកប់បញ្ចូលស្មៅ និងកាកសំណល់រុក្ខជាតិផ្សេងៗ ទៅក្នុងដីឲ្យរលួយ ក្លាយជាជីសម្រាប់ដំណាំស្រូវ និងងាយស្រួលក្នុងការគ្រប់គ្រងទឹក។ កសិករលាយច្របល់ ឬកប់បញ្ចូលជីធម្មជាតិទៅក្នុងដីដើម្បីកាត់បន្ថយការភាយសារជាតុចិញ្ចឹម(អាសូត) ទៅក្នុងខ្យល់ និងបង្កើនរន្ធខ្យល់ក្នុងដី។

នៅពេលស្ទូង កសិករស្ទូងក្នុងជម្រៅពី ១សម ទៅ ២ សម (ស្ទូងរាក់) ដោយមិនត្រូវបត់ឫសសំណាបដូចផ្លែសន្ទូច។ ជម្រៅស្ទូងអាចប្រែប្រួលទៅតាមប្រភេទដី ហើយត្រូវអនុវត្តដោយការប្រុងប្រយ័ត្ន។ ឧទាហរណ៍សម្រាប់ដីខ្សាច់ ក្នុងករណីមានទឹកគ្រប់គ្រាន់ ការស្ទូងរាក់ (ពី១សម ទៅ ២ សម) ជាការល្អ។ ប៉ុន្តែបើមានគ្រោះរាំងស្ងួតកើតឡើង ក្រោយពីស្ទូងហើយ នោះការស្ទូងរាក់នៅលើប្រភេទដីខ្សាច់អាចធ្វើឲ្យសន្ទូងងាយនឹងងាប់។ កសិករស្ទូងនៅចន្លោះគុម្ពសមស្របដោយប្រែប្រួល ទៅតាមប្រភេទដី ប្រភេទពូជ និងកម្រិតជីជាតិរបស់ដី។ ចន្លោះគុម្ពពី ២០សម គុណ ២០ សម សមស្របសម្រាប់ដីមិនសូវមានជីជាតិ។ រីឯចន្លោះគុម្ព ២៥សម គុណ ២៥ សម សមស្របសម្រាប់ដីសម្បូរជីជាតិ។

ចំណែកការគ្រប់គ្រងទឹក សម្រាប់តំបន់ដែលមានភ្លៀងធ្លាក់មិនសូវទៀងទាត់ ហើយធាប់រីងស្ងួត កសិករគួរយកចិត្តទុកដាក់លើកត្តាសំខាន់ខ្លះៗដូចជា ថែទាំភ្លឺស្រែឲ្យបានល្អ តែកុំរក្សាទឹកទុកច្រើនពេកក្នុងវគ្គលូតលាស់។ កសិករកំចាត់ស្មៅចង្រៃឲ្យអស់ពីស្រែ។ ប្រសិនបើធ្វើទៅបាន គួរជីកស្រះកណ្តាលស្រែទំហំពី ២០ម៉ែត្រ គុណ ១០ ម៉ែត្រ ដើម្បីងាយស្រួលបញ្ចេញបញ្ចូលទឹក។

ជាចុងក្រោយ ដើម្បីឲ្យស្រូវទទួលបានទិន្នផលខ្ពស់ កសិករត្រូវថែទាំស្រូវ ដោយកំចាត់កត្តាចង្រៃ មានដូចជាស្មៅជាដើម។ ដើម្បីគ្រប់គ្រងស្មៅចង្រៃឲ្យមានប្រសិទ្ធភាព កសិកររៀបចំដីស្រែឲ្យបានស្អាត និងរៀបស្មើ។ កសិករធ្វើស្មៅបំផុសដីយ៉ាងតិចពីរដង ឬប្រើឧបករណ៍ធ្វើស្មៅ។ ការធ្វើស្មៅបំផុសដីលើកទី១ ក្រោយស្ទូង ១៥ថ្ងៃ ជាការងារសំខាន់ ដែលជួយធ្វើឲ្យដីផុសមានខ្យល់ចេញចូល និងធ្វើឲ្យឫសលូតលាស់បានល្អ និងស្រូវកើនទិន្នផល៕

*ដោយ ផាត សំភី*



# យុវជនកម្ពុជាមិនសូវចាប់អារម្មណ៍នឹងការងារកសិកម្ម

ខណៈដែលវិស័យសេវាកម្ម និងឧស្សាហកម្មកាន់តែរីកចម្រើនស្របពេលដែលរោងចក្រឧស្សាហកម្ម ត្រូវបានពង្រីកពីទីក្រុងរហូតដល់បណ្ដាខេត្តមួយចំនួន បានធ្វើឲ្យយុវជនលែងសូវចាប់អារម្មណ៍នឹងការងារកសិកម្មបណ្ដើរៗហើយ ។

លោក សាញ់ សុវណ្ណ ដែលកំពុងតែរៀបចំម៉ាស៊ីនគោយន្តដើម្បីភ្ជួរដីមួយកន្លែងនៅសុក្រស្រីសន្ធ ខេត្តព្រៃវែង បានថ្លែងថា គាត់មានកូនប្រុសបីនាក់ ដែលពួកគេមានអាយុពី១៨ ដល់២៥ឆ្នាំ ប៉ុន្តែពួកគេមិនបាននៅផ្ទះនៅស្រុកកំណើតរបស់ពួកគេឡើយ ដោយពួកគេម្នាក់ៗនាំគ្នាទៅសិក្សា និងរកកាងារធ្វើនៅទីក្រុងភ្នំពេញអស់ហើយ ។

លោកសុវណ្ណ បានថ្លែងថា ក្មេងឥឡូវនេះ លែងមាននរណាចង់ធ្វើស្រែចំការទៀតហើយ ។ ម្នាក់ៗពួកគេគិតតែទៅរកការងារល្អៗនៅទីក្រុង ។

លោកសុវណ្ណបានបញ្ជាក់ថា "កូនគេកូនខ្ញុំ តែធំដឹងក្ដី គឺគ្មាននរណាចង់កាន់គោក្របី ចប នង្គ័ល អីទៀតហើយ ម្នាក់ៗដឹងតែចង់ទៅពាក់ក្រវ៉ាត់ករ" ។

តាមការរៀបរាប់របស់ លោក សុវណ្ណ កូនរបស់គាត់ទីមួយ គឺកំពុងតែធ្វើការជាវិស្វករសំណង់មួយរូប នៅក្នុងរាជធានីភ្នំពេញ ខណៈទីពីរ គឺកំពុងតែសិក្សា ដូចជា កុំព្យូទ័រ និងអង់គ្លេស ហើយទីបី គឺ កំពុងតែសិក្សា ផ្នែកធនាគារ ។ ពួកគេគ្មាននរណាចាប់អារម្មណ៍ នឹងការធ្វើស្រែចំការ ដែលលោក និងភរិយាបានប្រកបរបរតាំងពីក្មេងមករហូតដល់ចិញ្ចឹមពួកគេធំធាត់រហូតដល់បច្ចុប្បន្ននេះទេ ។

លោក ច័ន្ទ ភាគ ជាកសិករមួយរូប កំពុងតែប្រមូលល្ងនៅស្រុក កោះសុទិន ខេត្តកំពង់ចាម ក៏បានឲ្យ ដឹងអំពីទឹកចិត្តយុវជន និងយុវនារី ដែលជាកូនៗរបស់លោក ព្រមទាំងអ្នកភូមិរបស់លោកផងដែរ ។

លោកបានថ្លែងបន្តទៀតថា "សូមដើរមើលទៅ មានឃើញ យុវជន ឬយុវនារីណា ដែលនៅជួយប្រមូលផលល្ង ឬបុិកក់អី នៅតាមចំការ តាមស្រែ អីទេ.... ឲ្យតែដឹងក្ដីអាយុ ១៦ឆ្នាំអីឡើងទៅ ជ្រើមចេញពីផ្ទះពីស្រែទៅ ទីក្រុងអស់ហើយ" ។

លោកបានបន្តទៀតថា ឥឡូវនេះ បើសួរទៅក្មេងតាមស្រុកស្រែចំការ ចម្លើយប្រហែលជា ១០០ ទាំង ១០០គឺថា មិនមានអ្នកណាចាប់អារម្មណ៍ នឹងការងារកសិកម្មឡើយ ។ ក្មេងៗដែលនៅក្នុងគ្រួសារ គេមានជីវភាពធូរធារទៅ គេទៅរៀនបន្តនៅឯទីក្រុងទៅ ចំណែកក្មេងៗនៅក្នុងគ្រួសារដែលខ្វះខាត គឺពួកគេទៅធ្វើការនៅតាមរោងចក្រ ហើយខ្លះទៀតទៅធ្វើនេះធ្វើនោះ នៅទីក្រុង ។

កញ្ញា ឡេង ណៃហៀង ដែលជាកម្មការិនីរោងចក្រមួយម៉ឺ ផ្សារអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានឲ្យដឹងថា ការងាររោងចក្រវាមិនស្រួលទេ តែវាបានលុយជាប្រចាំ ។ ពោលគឺដឹងតែដល់ខែ បើកលុយ ។

តាមការឲ្យដឹងរបស់ណៃហៀង គឺថា ការងារធ្វើស្រែនេះ គឺវាមិនជាពិបាកអីដល់រោងចក្រនោះទេ ប៉ុន្តែខុសត្រង់ថា វាមិនបានលុយជាប្រចាំ ដូចជាមកធ្វើជាកម្មការិនីរោងចក្រ ។

កញ្ញាបានបញ្ជាក់ថា "បើធ្វើស្រែគឺបានតែម៉ាហូបៗហ្នឹង បានលុយណាចាយ ចឹងហើយបានខ្ញុំសុខចិត្ត មកធ្វើការរោងចក្រយកលុយទៅជួលគេធ្វើស្រែជំនួស" ។

កញ្ញាបានបន្តទៀតថាបើទោះបីជាកញ្ញាមកធ្វើជាកម្មការនីរោងចក្រក៏ពិតមែនក៏មិនមែនមានន័យថា កញ្ញាបំភ្លេចការងារស្រែចំការដែរ ដោយសារតែ នាង គឺយកលុយចំណែកខ្លះសន្សំទុក សម្រាប់ជួលគេធ្វើ ពីព្រោះស្រែក៏អាចផ្ដល់អង្ករ សម្រាប់នឹងទទួលទានបានពេញៗមួយឆ្នាំដែរ ។

យុវជន សែម បញ្ញាបុត្រ ជានិស្សិតផ្នែកស្ថាបត្យកម្មមួយរូប បានឲ្យដឹងថា រូបគេក៏ជាកូនកសិករមួយរូប នៅក្នុងខេត្តបាត់ដំបង ប៉ុន្តែតាំងពីតូចមក មិនដែលបានស្គាល់ការងារធ្វើស្រែយ៉ាងម៉េចនោះទេ ដោយសារតែគ្រួសារបេះតែឧបត្ថម្ភ និងជំរុញឲ្យតែរៀនតែប៉ុណ្ណោះ ។

បញ្ញាបុត្រ បានឲ្យដឹងថា លោកមានបងប្អូន២ នាក់ ប៉ុន្តែគ្មានអ្នកណានៅផ្ទះទេ (ផ្ទះនៅស្រុក) ដោយឪពុកម្ដាយ លោកបានបញ្ជូនលោក និងបងប្រុស ឲ្យមករៀននៅភ្នំពេញ ។

បញ្ញាបុត្រ បានបន្តទៀតថា កាលនៅក្មេងៗ រូបគេក៏ធ្លាប់ ចាប់អារម្មណ៍ ហើយជួយកិច្ចការស្រែចំការនេះ នៅផ្ទះផងដែរ ប៉ុន្តែ ដល់រៀនរៀងខ្ពស់ អាណាព្យាបាលប្អូន ក៏បានលើកទឹកចិត្តប្អូនឲ្យខំប្រឹងតែសិក្សា ដើម្បីកុំឲ្យប្អូន និងបងប្រុសធ្វើការលំបាកលំបិន ស្រែដូចជាពួកគាត់ទៀត ។

ទាំងនេះ គឺជាទិដ្ឋភាពមួយជ្រុងតូចដែលជាប់ពាក់ព័ន្ធនឹងវិស័យកសិកម្ម នៅកម្ពុជា ប៉ុន្តែជារួមមកវិស័យនេះនៅតែជាវិស័យអទិភាព និងជាប្រភពមួយដ៏ចំបងសម្រាប់កំណើនសេដ្ឋកិច្ចជាតិ ។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានថ្លែងនាពេលចូលរួមសម្ពោធ បើកផ្សារណាត់បន្លែសុវត្ថិភាព និងផលិតផលមានសុវត្ថិភាព កាលពី ថ្ងៃទី០៤ ខែកក្កដា ថា វិស័យកសិកម្មកម្ពុជានៅមានបញ្ហាប្រឈមច្រើន ប៉ុន្តែវិស័យនេះនៅតែជាវិស័យគន្លឹះ នឹងជាប្រភពនៃ កំណើនសេដ្ឋកិច្ច ដូច្នេះហើយ ទើបក្រសួង បានកំពុងតែដាក់ចេញ នូវយុទ្ធសាស្ត្រ និងផែនការជាច្រើននៅក្នុងគោលបំណង ជំរុញវិស័យនេះ ឲ្យទៅជាវិស័យដែលរឹតតែសំខាន់ ។

លោកបានបញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយនៅក្នុងវិស័យនេះ ក៏ដូចជាពង្រឹងវិស័យ ដែលជាវិស័យមូលដ្ឋាននៃសេដ្ឋកិច្ចជាតិនេះ គឺក្រសួងបានកំពុងផ្ដល់ជា ចក្ខុវិស័យ និងការរៀបចំកសាងគោលនយោបាយជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យកសិកម្មជាតិ សម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០ ដែលត្រូវប្រែក្លាយកសិកម្មកម្ពុជាទៅជាកសិកម្ម ទំនើបមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តភាព ដែលនាំដល់ការកើនឡើងនៃប្រាក់ចំណូលគ្រួសារកសិករស្របតាមកំណើនសេដ្ឋកិច្ចប្រកបដោយវិបុលភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា ៕

*ដោយ អរិយបុត្រ*



ថតដោយ: កញ្ញា

# ទស្សនៈយុវជន៖ ការចូលហាងកាហ្វេប្រេនៗមិនមែនរឿងញៀនទេ តែជារឿងទាន់សម័យ



ថតដោយៈ លី សុវណ្ណា

បច្ចុប្បន្ននេះនៅទីណាដែលមានហាងកាហ្វេប្រេនៗល្បីៗ គឺសុទ្ធតែពេញទៅដោយអតិថិជនជាពិសេស គឺស្រទាប់យុវវ័យ និងមនុស្សវ័យកណ្តាលដែលមើលទៅទំនងដូចជាពលរដ្ឋកម្ពុជាកំពុងតែញៀននឹងកាហ្វេទាំងនោះ ប៉ុន្តែនៅពេលសាកសួរ នឹងដឹងថា ភាគច្រើនពួកគេមិនមែនជាអ្នកញៀនកាហ្វេទេ តែការបង្ហាញពីភាពស៊ីវិល័យទាន់សម័យ ។

នេះគឺជាអំណះអំណាងដែលបានមកពីការដកស្រង់សំដីយុវជនមួយចំនួននៅតាមហាងកាហ្វេផ្សេងៗគ្នា ដែលមាននៅក្នុងទីក្រុងភ្នំពេញកាលពីពេលថ្មីៗនេះ។

យុវជន ឈាង សុផាន់ណា ដែលមានវ័យ ២៣ឆ្នាំ ជានិស្សិតផ្នែកព័ត៌មានវិទ្យាមួយរូប បានអះអាងថា រូបគេមិនចេះផឹកកាហ្វេទេ ប៉ុន្តែគេចូលចិត្តចូលហាងកាហ្វេ។

សុផាន់ណា បានអះអាងថា "ខ្ញុំចូលហាងកាហ្វេសឹងតែរាល់ថ្ងៃហ្នឹង តែខ្ញុំញ៉ាំតែ តែបៃតងក្រឡុក ឬសូកូឡា ឬពពួកផ្លែឈើក្រឡុក ដូចជាស្ត្រប៊េរីហ្វ្រេប្រ ប៉ុណ្ណោះ"។

ផន ទេពី ដែលជាយុវនារីនិស្សិតវ័យ ២២ឆ្នាំ កំពុងសិក្សាភាសាអង់គ្លេសបានឲ្យដឹងថា កញ្ញាចូលហាង កាហ្វេទាំងនោះ គឺចេះតែចូលតាមគេតាមឯងប៉ុណ្ណោះ។

ទេពី បានបញ្ជាក់ថា "ខ្ញុំមិនមែនជាអ្នកញៀនកាហ្វេអីទេ! ខ្ញុំចេះតែចូលៗតាមគេតាមឯង តាមពួកម៉ាក បបួល ប៉ុណ្ណោះ"។

យុវនិស្សិត ស្ថាបត្យកម្ម ជ័យ បញ្ញាវ័ន្ត ដែលជាអ្នកគាំទ្រហាងកាហ្វេប្រេនៗមួយរូបដែរនោះ បានអះអាងថា ការចូលហាងកាហ្វេស្អាតៗ គឺដូចជា ជីវសង្គមស៊ីវិល័យមួយដែរ ដោយសារតែសម័យនេះ ភាគច្រើនគេចូលចិត្តអីចឹង។

បញ្ញាវ័ន្ត បានអះអាងបញ្ជាក់ថា "នេះជាឡាហ្វស្តាយ(lifestyle)យុវវ័យសម័យថ្មី។ សម័យនេះ តែអត់ស្គាល់ កាហ្វេឡាតេ កាហ្វេ កាពូជីណូ អីគេថាវាមិនទាន់សម័យ"។

ទាំងនេះគឺជាទស្សនៈរបស់យុវជននិងយុវនារីកម្ពុជាទាក់ទងនឹងការគាំទ្រ និងការពេញនិយមនៃប្រភេទសេវាកម្មកាហ្វេប្រេនៗ នៅក្នុងប្រទេសជាពិសេសគឺនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និងនៅខេត្តព្រះសីហនុ ក៏ដូចជាតាមទីប្រជុំជននានា។

ជុំវិញចំណុចនេះ យុវជន សុផាន់ណា បានអះអាងថា ការគាំទ្រហាងកាហ្វេប្រេនៗនេះវាមិនមែនមកតែពីរឿងទាន់សម័យ ឬឡាហ្វស្តាយថ្មីអ្វីនោះទាំងអស់ទេ វាអាចមកពីបរិយាកាស ហាងទាំងនេះរៀបចំ ស្អាតមានកៅអីអង្គុយស្រួល ការរៀបចំតុបតែងហើយមើលទៅមានអនាម័យ ដែលខុសប្លែកពីហាងកាហ្វេសម័យមុនៗ។

សុផាន់ណា បានបន្តទៀតថា ប្រៀបធៀបរវាងហាងកាហ្វេប្រេនៗនេះទៅនឹងហាងកាហ្វេ នៅក្នុងស្រុក វាដូចជាមិនដឹងយ៉ាងម៉េចទេ។ ដោយសារតែហាងបែបប្រពៃណី គឺដូចជាមានបញ្ហារឿងអនាម័យ ហើយបរិកាសក៏ដូចជារញ៉េរញ៉ៃបន្តិច។

សុផាន់ណាបានលើកឡើងថា " ហាងកាហ្វេដូចជា នៅតាមផ្សារអូឫស្សី ផ្សារអូឡាំពិក អ្នកណាចង់ជក់បារីជក់ទៅ ចង់ស្តោះទឹកមាត់ស្តោះទៅតែនៅតាមហាងប្រេនៗ គឺមិនចឹងទេ គេស្អាត គេមានរបៀប គេមានការរៀបចំត្រឹមត្រូវ"។

ដោយឡែកកញ្ញាទេពីវិញ បានបង្ហាញចំណាប់អារម្មណ៍ផ្សេងមួយទៀតថា រឿងបរិយាកាស រឿងអនាម័យអី វាគឺជារឿងមួយ ប៉ុន្តែហាងកាហ្វេតាមផ្សារ នៅក្នុងស្រុក គឺអត់មានជម្រើសអីច្រើនទេ គឺមានតែកាហ្វេខ្មៅ កាហ្វេទឹកដោះគោ ទឹកក្រូចទឹកផ្លែឈើកំប៉ុង ផ្ញុំផ្ញូវ អីហ្នឹងទេ ប៉ុន្តែនៅតាមហាងកាហ្វេប្រេន គេមានច្រើនមុខ។ គ្រាន់តែកាហ្វេនោះ វាមាន អ៊ិចប្រេសូ គេមានអាមេរិកខេនណូ គេមាន កាពូស៊ីណូ កាហ្វេឡាតេ ...។

កញ្ញាទេពី បានបន្តទៀតថា អាហារក៏ដូចគ្នាដែរ តាមហាងកាហ្វេប្រេនៗនោះ ភាគច្រើនមិនសូវជាមាន អាហារអីច្រើន នាំឲ្យហាងគេឆ្អេះឆ្អាបអីនោះទេ គឺថា តែពពួកកាហ្វេ ពពួកហ្វេប្រប៉ុណ្ណោះ ហើយបើអាហារវិញ គឺមានត្រឹមតែជានំ ដូចជាពពួក ប៊ីស្គិត ពពួកអាហារសម្រន់លឿនៗ។

កញ្ញាទេពី បានបញ្ជាក់ថា "កាហ្វេប្រេនឬមិនប្រេនវាមិនសំខាន់ទេ សំខាន់គឺអ្នកណាចង់អីទៅហ្នឹងទៅ។ បើចង់គុយទាវប្រហិត មានទឹកសៀង ទឹកម្ទេស ខ្ទឹមជ្រក់ ឬនំប៉ាវ... ទៅហ្នឹងទៅ ហើយអ្នកចង់បានកន្លែងស្អាត គឺទៅទីនោះទៅ"។

ដោយឡែក យុវនិស្សិត បញ្ញាវ័ន្ត វិញ បានបន្តចែករំលែក នូវឡាហ្វស្តាយបែបថ្មីរបស់យុវវ័យនៅហាងកាហ្វេប្រេនៗនេះ ថាមូលហេតុដែលហាងកាហ្វេប្រេនៗនេះ អាចទាក់ទាញអតិថិជនក្មេងៗ និងមនុស្សវ័យកណ្តាលច្រើន គឺវាអាចថា ទីនោះមាន WiFi (ឧបករណ៍ភ្ជាប់អ៊ីនធើណែតឥតខ្សែ) មានកន្លែងអង្គុយសមរម្យស្ងប់ស្ងាត់ អាចជាកន្លែងងាយស្រួលនៅក្នុងការធ្វើកិច្ចការ ធ្វើការស្រាវជ្រាវ ធ្វើកិច្ចការសាលា។

បញ្ញាវ័ន្ត បានបញ្ជាក់ថា "ដូចជាក្រុមខ្ញុំអីចឹង គឺឲ្យតែថ្ងៃសៅរ៍អាទិត្យ គឺតែងតែជុំគ្នានៅធ្វើAssignment (កិច្ចការសាលា) នៅតាមហាងកាហ្វេប្រេនៗនេះជានិច្ច។ ហើយបើកន្លែងណាពេញយើងទៅកន្លែងមួយទៀត។ កន្លែងណាក៏ដូចជាកន្លែងណា ឲ្យតែទំនេរមានកន្លែងអង្គុយ សម្រាប់ក្រុម ៤ទៅ ៥ នាក់បាន"។

រហូតមកដល់ពេលនេះ ហាងកាហ្វេប្រេនៗដែលពេញនិយម ហើយកំពុងតែល្បី និងមានការគាំទ្រដូចមានជាច្រើន ដូចជា ហាងកាហ្វេ ប្រោន ស៊ីក្លូ អាម៉ាហ្សូន ស្តាបាក ផាមកាហ្វេ កាហ្វេធូដេ ចូម៉ាកាហ្វេ ប៊ីខេកាហ្វេ រ៉េស័រកាហ្វេ...។ល។ ហាងកាហ្វេទាំងនោះ ត្រូវបានគេដឹងថា ខ្លះជាយីហោ ឬជាប្រេននៅក្នុងស្រុកខ្លះត្រូវបានគេដឹងថា បានទិញយីហោរពីបរទេសមានពីអ៊ីតាលី ពីថៃ ពីអាមេរិក...។

យុវជនជាបុគ្គលិកនៅហាងកាហ្វេប្រេនមួយកន្លែងនៅម្តុំទួលទំពូង បានឲ្យដឹងថា ជាទូទៅបណ្តាអ្នកជាអតិថិជននៅហាងរបស់ខ្លួនបម្រើការងារ គឺភាគច្រើនជាយុវវ័យ និងមនុស្សវ័យកណ្តាល ប៉ុន្តែភាគច្រើនយុវវ័យមិនសូវជាចូលចិត្តកាហ្វេទេ។ ពួកគេចូលចិត្តតែពពួក សូកូឡា ក្រឡុក ដូចជាតែបៃតង ។

យុវជនរូបនោះ បានបញ្ជាក់ថា " ពពួកកាហ្វេខ្លាំងៗ ដូចជា អាមេរិកខេនណូ អ៊ិចប្រេសូអី គឺមានតែបរទេស និង អ្នកដែលមានវ័យចំណាស់បន្តិចប៉ុណ្ណោះ តែយុវវ័យ ពួកគេចូលចិត្ត កាហ្វេបែបស្រាលៗ ដូចជា កាហ្វេឡាតេ ឬទឹកផាសិន សូដា ឬក្រឡុក ..."៕

ដោយ អរិយបុត្រ

# កម្មករ និងកម្មការិនីកម្ពុជានៅតែមានអ្នកដែលមិនចេះអក្សរ

បើទោះបីជាអត្រាអនក្ខរកម្មនៅក្នុងចំណោមពលរដ្ឋមានការថយចុះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយនៅក្នុងមជ្ឈដ្ឋានកម្មករនិងកម្មការិនីនិយាយឲ្យចំនៅក្នុងចំណោមអ្នកដែលបម្រើការងារ ដោយកម្លាំងនៅក្នុងវិស័យនានា នៅតែប្រឈមនឹងបញ្ហាគ្រោះមិនចេះអក្សរ។

កម្មករនិងកម្មការិនីរោងចក្រកាត់ដេរ កម្មករនិងកម្មការិនីនៅតាមការដ្ឋានសំណង់ កម្មករនិងកម្មការិនីនៅតាមរោងហត្ថកម្មឈើ និងកន្លែងធ្វើការដោយកម្លាំងនានានៅក្នុងប្រទេស គឺនៅតែ មាន កម្មករនិងកម្មការិនីដែលមិនចេះអក្សរ ។

លោកស្រី លឹម សៀវហ៊ីម ដែលជាកម្មការិនីរោងចក្រកាត់ដេរវ័យ ៣៤ឆ្នាំមួយរូប បានឲ្យដឹងថា លោកស្រីអាចអានបាន ប៉ុន្តែវានៅតែជាការលំបាកសម្រាប់លោកស្រី ដោយសារតែ លោកស្រី គ្មានពេលវេលានឹងអាន ។

លោកស្រី បានបញ្ជាក់ថា "ខ្ញុំរៀនបានតិចណាស់ អាចអានបាន បើខំ ប៉ុន្តែវាគ្មានពេលនឹងរៀន បើម៉ាថ្ងៃៗរវល់តែរហូតរកតែដកខ្លួនទម្រេតសឹងមិនចង់បាន។ ធ្វើការផង ធ្វើម្ហូបផង មើលកូនផង"។

បើតាមការអះអាងរបស់លោកស្រី សៀវហ៊ីម បានឲ្យដឹងថា លោកស្រីមិនមែនមិនបានរៀនសូត្រទេ។ លោកស្រីធ្លាប់រៀនបាន ថ្នាក់ទី៤ ឬទី៥ ដែរ។ លោកស្រីអាចចេះត្រឹមអានបើខំស្ទះស្ទែងអាន ប៉ុន្តែលំបាកបន្តិចរឿងសរសេរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ឱកាសនៃការអានរបស់លោកស្រីសឹងតែគ្មានចាប់តាំងពីលោកស្រីបម្រើការជាកម្មការិនីរោងចក្រ ប្រហែលជាជាង ១០ឆ្នាំមកនេះ ។

លោកស្រីបានបញ្ជាក់ថា "ការងារខ្ញុំវាអត់ពាក់ព័ន្ធអីនឹងការអានសោះហ្នឹង ចឹងបានភ្លេចចង់អស់ ហើយអ្នកខ្លះគេធ្វើជួយខាងវត្តមាន អីទៅចឹងគេបានអាចខ្លះគេចេះតែខ្ញុំគ្មានទេ មួយថ្ងៃៗគឺដឹងតែពីឈ្ងោកដេរដល់ម៉ោងទៅផ្ទះ ធ្វើម្ហូបមើលកូនទៀត"។

កញ្ញា ស៊ុន ពិសី ជាកម្មការិនីរោងចក្រកាត់ដេរមួយរូបនៅម្តុំគីឡូម៉ែត្រលេខ ៦ ជិតស្ថានីយ ទូរទស្សន៍ ស៊ីធីអេន បានអះអាងថា កញ្ញា ក៏ធ្លាប់បានរៀនសូត្រនឹងគេដែរគ្រាន់តែមិនជ្រៅជ្រះ ។ កញ្ញាបានបន្តទៀតថា បើត្រឹមតែអាន គឺអាចអានបានតែសរសេរគឺយ៉ាប់ ដោយសារតែរៀនបានត្រឹមថ្នាក់ទី៦។ កញ្ញា បានបន្តទៀតថា ឥឡូវកញ្ញាចង់រៀនបន្តទៀតដែរ តែអាយុវិញវាជាង ២០ឆ្នាំហើយ មិនអាចទៅរៀនវិញទេ ចឹងបានថាតាមយថាកម្មទៅ ។

កញ្ញាបានបន្តថា មូលហេតុដែលកញ្ញាបានបោះបង់ការសិក្សាគឺគ្មានអ្វីក្រៅពីលុយនោះទេ ដោយកាលនោះកញ្ញាបានបោះបង់ការសិក្សា ប្រហែលជានៅអាយុ ១៣ទៅ ១៤ឆ្នាំ ដោយគ្រួសារអត់ក៏ចេះមករកការងារធ្វើនៅតាមផ្ទះគេជាអ្នកមើលកូន និងបោសជូតផ្ទះឲ្យគេនៅភ្នំពេញ។ កញ្ញា បានបន្តទៀតថា កាលនៅជាមួយគេ (ពលការិនីតាមផ្ទះ) កញ្ញា បានចេះអាន ចេះអក្សរបានច្រើន ដោយនៅជាមួយក្មេងៗគេអ្នករៀនសូត្រ គេចេះតែនាំកញ្ញាអាននេះអាននោះសួរនេះសួរនោះ ក៏ចេះតាមពួកគេ តែតាំងពីធ្វើការនៅរោងចក្រមក គឺសឹងតែអត់សោះហ្នឹងរឿងអាន សរសេរនេះ។

កញ្ញាបានបញ្ជាក់ថា "មួយខែទៅមួយខែសឹងថា ដល់ឆ្នាំទៅទៀត មិនដែលបានអានបានសរសេរស្អីទេ គឺមួយថ្ងៃដឹងតែវែបុង ស្តេនមេដៃហើយធ្វើការ។ ចេញពីធ្វើការទៅបន្ទប់ញ៉ាំ ហើយគេងតែប៉ុណ្ណឹង"។

លោក សឹម ចាន់ ជាកម្មករសំណង់នៅការដ្ឋានសំណង់មួយ នៅម្តុំផ្លូវនរោត្តម ជិតក្រសួងវប្បធម៌ បានអះអាងថា នៅម៉ោងសម្រាកថ្ងៃត្រង់ដោយខ្លីថា លោកធ្លាប់រៀនចេះអានចេះសរសេរខ្លះដែរ ប៉ុន្តែឥឡូវនេះភ្លេចចង់អស់ហើយ។

លោកចាន់ដែលមានវ័យ ២៦ឆ្នាំ បានអះអាងថា លោកបានរៀនថ្នាក់ទី ៧ ទៅទី ៨ អីដែរ តែគ្រួសារ អត់ ក៏ចេញមករកការងារធ្វើ ហើយក៏ចោលលែងអានលែងសរសេរ ដូច្នេះឥឡូវនេះសឹងតែមិនចេះអានផង។

លោក ចេង សំអាង ជាកម្មករនៃក្រុមហ៊ុន ស៊ីនទ្រី ដែលអះអាងថា មានអាយុ ២៦ឆ្នាំ បានឲ្យដឹងថា រៀនបានតិចតួច កុំថា ចេះអី។ លោកបានបន្តថា រៀនត្រឹមថ្នាក់ទី៣ទី៤អី កុំថា បានរៀនចេះអានចេះសរសេរអី ពីព្រោះតែជីវភាពតម្រូវ។

រហូតមកដល់ពេលនេះ អត្រាអនក្ខរកម្មនៅកម្ពុជាអាចមាននៅក្រោម១៥ភាគរយនៃប្រជាពលរដ្ឋ សរុបខណៈដែល ក្រសួងអប់រំ យុវជននិងកីឡា កំពុងតែ ពន្លឿនកម្មវិធីអក្ខរកម្ម ដើម្បីបំពេញ គោលដៅនៃការអប់រំសម្រាប់ទូទាំងប្រទេស បានលើសពី ៨៥ភាគរយ។

ទាក់ទិននឹងបញ្ហាអនក្ខរកម្ម និងអក្ខរកម្មនេះ លោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ធ្លាប់បានថ្លែងថា អត្រាអនក្ខរកម្មនៅតាមតំបន់ជនបទនៅតែមានកម្រិត ខ្ពស់ជាងតំបន់ប្រជុំជនក្នុងនោះចំនួនស្ត្រីអនក្ខរកម្មមានកម្រិតខ្ពស់ជាងបុរស។

លោកបានថ្លែងថា បញ្ហាអនក្ខរកម្ម គឺជាកង្វល់របស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួង ដោយសារ តែយើងនៅមានអនក្ខជនជាងមួយលាននាក់ទៀត ជាហេតុនាំឲ្យក្រសួង បានរៀបចំបញ្ហានេះ ជាសមាភាពមួយ មិនអាចខ្វះបានក្នុងវិស័យអប់រំ។ វាគឺជាកម្មវិធីមួយ ដ៏មានអទិភាពដ៏ចម្បងតាម រយៈកម្មវិធីអប់រំក្រៅប្រព័ន្ធ។

តាមរបាយការណ៍ពីក្រសួង ពាក់ព័ន្ធនឹងកម្មវិធីអប់រំក្រៅប្រព័ន្ធនេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងតែសហការជាមួយ អង្គការស៊ីប៉ា និងអង្គការយូណេស្កូ កំពុងតែដំណើរការ កម្មវិធីនេះ នៅតាមរោងចក្រមួយចំនួន ។

ប្រភពដដែលបានឲ្យដឹងថា ចាប់ពីឆ្នាំ ២០១៦ មកដល់ពេលនេះ កម្ពុជាមានរោងចក្រចំនួន២៥ បានចូលរួម និងសហការ ក្នុងកម្មវិធី "អក្ខរកម្មក្នុងរោងចក្រ" ដោយកម្មវិធីនេះ មានទិសដៅលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិត សម្រាប់កម្មករ កម្មការិនី ដែលពុំចេះអក្សរ។

ប្រភពដដែលបានបន្តទៀតថា មកដល់ពេលនេះកម្មការិនី ដែលបានចូលរៀនក្នុងថ្នាក់អក្ខរកម្ម ពួកគេមានការរីកចម្រើនក្នុងការអាន សរសេរ និងបំនិនគិតលេខ។ ពួកគាត់អាចយល់ពីព័ត៌មាន ដែលផ្សព្វផ្សាយក្នុងរោងចក្រ ហើយក៏អាចអានបាននូវលក្ខខណ្ឌការងារ និងឯកសារចាំបាច់នានា៕

*ដោយ អរិយបុត្រ*



ថតដោយ: ហ្វេសបុក អង្គការស៊ីប

# សមាគមគម្ពីរក៏ជាក្រុមការងារសង្គមដ៏សកម្មមួយនៅកម្ពុជា


លោក ហេង ពិសិដ្ឋ

*សមាគមគម្ពីរ ត្រូវបានគេដឹងជាទូទៅថា ជាសមាគមមួយ ដែលកំពុងតែជួយផ្សព្វផ្សាយនូវគោលលទ្ធិគ្រីស្តសាសនា នៅកម្ពុជា ប៉ុន្តែជាតុពិតសមាគមនេះក៏ជាស្ថាប័នសង្គមមួយ ដែលសកម្មនៅក្នុងផ្នែកអប់រំ និងសកម្មភាពសង្គមផ្សេងៗទៀត ដូច្នេះលេខនេះអ្នកនាំសារ សូមអនុញ្ញាតនាំមិត្តអ្នកអានឲ្យជួបជាមួយនឹងលោក ហេង ពិសិដ្ឋ ជានាយកប្រតិបត្តិសមាគមនេះ។*

**អ្នកនាំសារ៖** តើនៅក្នុងរយៈពេល ៥០ ឆ្នាំកន្លងមក សមាគមគម្ពីមានសកម្មភាពអ្វីខ្លះ?

**លោកហេង ពិសិដ្ឋ៖** បាទ! ការពិតការកកើតនូវសមាគមព្រះគម្ពីឡើងវិញ យើងផ្តោតទៅលើការបោះពុម្ពព្រះគម្ពីរ និងចាយផ្សាយទៅគ្រីស្តបរិស័ទក្នុងប្រទេសកម្ពុជា។ ដោយឡែក គម្រោងផ្សេងៗយើងអត់បានធ្វើនៅឡើយទេ ដោយសារយើងនៅក្មេងខ្ចីពេក ប៉ុន្តែមកដល់បច្ចុប្បន្នកាលនេះ យើងមានគម្រោងច្រើនដែរដូចជាយើងបានជួយដល់សហគមន៍គ្រីស្តបរិស័ទ យើងមិនមែនតែបោះពុម្ព និងចាយផ្សាយគម្ពីរទេ យើងថែមទាំងមានគម្រោងផ្សេងៗដូចជាគម្រោងអក្ខរកម្មដោយយើងដំណើរការមកដល់ពេលនេះ១៥ឆ្នាំហើយ។ ហើយអក្ខរកម្មនឹងគឺយើងប្រើប្រាស់ យើងហៅថាកម្មវិធីអក្ខរកម្មតាមការស្តាប់ និងតាមការអាន។ កម្មវិធីអក្ខកម្មនេះយើងអត់ត្រូវការ ការប្រើប្រាស់គ្រូបង្រៀនទេ តែយើងប្រើប្រាស់ MP3 & SD Card ដើម្បីចាក់មេរៀនឲ្យកូនសិស្សស្តាប់ ដោយប្រើប្រាស់អ្នកសម្របសម្រួលក្រុម។ ដូច្នេះកូនសិស្សនឹងអានតាមដោយក្នុងនោះសិស្សមានសៀវភៅដោយសៀវភៅចែកជូនកូនសិស្សដោយឥតគិតថ្លៃតែនៅពេលរៀនចប់យើងប្រគល់ជូនគាត់នូវព្រះគម្ពីរ១ក្បាលអំពីសម្ពន្ធមេត្រីថ្មី និងសៀវភៅតូចៗផ្សេងៗទៀតដើម្បីជំនួយនៅការអានបន្តរបស់គាត់ និងបញ្ចប់គាត់បានទទួលសញ្ញាប័ត្រផ្សេងៗផងដែរ នេះជាគម្រោងទី១។ នេះជាគម្រោងមួយចំនួនដែលយើងធ្លាប់មាន ហើយយើងមានគម្រោងជាច្រើនទៀតដែលពីមុនៗមក មុនពេលខ្ញុំមកដល់សមាគមព្រះគម្ពីរនេះ មានដូចជា ការផ្សះផ្សា ការព្យាបាលដួងចិត្តតាមរយៈការអត់ទោស យើងប្រើប្រាស់សិល្បៈបុរាណខ្មែរដើម្បីនឹងនិយាយទៅកាន់ប្រជាជនខ្មែរតាមរយៈការអត់ទោស។ យើងឃើញថាយើងធ្វើបានពីរដងហើយគឺនៅភ្នំពេញម្តងនិងនៅសៀមរាបម្តង ហើយយើងឃើញថាល្អ។

**អ្នកនាំសារ ៖** ខ្ញុំលឺថា បច្ចុប្បន្ននេះសមាគមព្រះគម្ពីរដូចជាមានរៀបចំសៀវភៅគម្ពីរថ្មីដៃសរសេរដោយដៃរបស់គ្រីស្តបរិស័ទម្នាក់ៗ តើគម្រោងនេះយ៉ាងម៉េចវិញ លោកគ្រូអាចជួយជម្រាបបានទេ?

**លោកហេង ពិសិដ្ឋ៖** នេះជាអ្វីដែលដក់នៅក្នុងដួងចិត្តខ្ញុំ។ ពេលខ្ញុំបានទៅប្រទេសហ្វីលីពីន ខ្ញុំបានឃើញព្រះគម្ពីរដែលសរសេរដោយដៃ ដែលគ្រីស្តបរិស័ទនៅប្រទេសហ្វីលីពីនគេនាំគ្នាមកសរសេរព្រះគម្ពីរតែម្តង ហើយវាធ្វើឲ្យខ្ញុំរំភើប។ ខ្ញុំទៅតែវ៉ាន់ខ្ញុំឃើញព្រះគម្ពីរសរសេរដោយដៃទៀត។ ខ្ញុំគិតថាហេតុអ្វីបានជាគេគ្រប់គ្នាធ្វើអីចឹងខ្មែរម៉េចក៏អត់ទាន់មាន? ខ្ញុំក៏បំផុសគំនិតជាមួយបុគ្គលិកយើង មានន័យថាមនុស្សម្នាក់ គ្រីស្តបរិស័ទម្នាក់គាត់អាចសរសេរ១ ខ,២ខ,៣ខ ឬ១ជំពូក ក៏បានដែរ នៅក្នុងសម្ពន្ធមេត្រីថ្មី។ គាត់ចាប់ផ្តើមសរសេរ ហើយគាត់ពេញចិត្តខមួយណាមើលទៅតែបើម្នាក់ពេញចិត្តខនោះ ម្នាក់ពេញចិត្តខនោះដូចគ្នា អ្នកណាមកមុនក៏សរសេរគាត់យកមុនហើយ គាត់ក៏ដូរផ្សេង។ យើងប្រើក្រដាសA3ពីដង បើយើងបូកទៅបើចប់យើងចងក្រងជាសៀវភៅ ហើយប្រវែងសៀវភៅជិត១ម៉ែតឯណោះ ហើយវាជាកេរមរតកសម្រាប់កូនចៅជំនាន់ក្រោយ។ ខ្ញុំជឿថានៅពេលខាងមុខវិទ្យាសាស្ត្រកាន់តែជឿនលឿន ហើយការសរសេរនឹងកាន់តែបាត់បង់តែអ្វីដែលនៅក្នុងកុំព្យូទ័រវាចេះកាន់តែច្រើនឡើងវិញ ដូចនេះវាជាមរតកមួយជំនាន់យើង តែគម្ពីរសរសេរដៃជាមរតកមួយសម្រាប់ជំនាន់ក្រោយ មួយជំនាន់ទៀត កូនខ្ញុំ ចៅខ្ញុំ ចៅទួតខ្ញុំ ប្រសិនបើព្រះអង្គ (ព្រះយេស៊ូ)មិនទាន់យាងមកដល់ទេបន្តដល់ថ្ងៃនឹង។ អីចឹងហើយខ្ញុំគិតថានេះជាអ្វីដែលគេបន្សល់ដល់ប្រជាជនខ្មែរជំនាន់យើងនេះ គួរចាប់ផ្តើមបន្សល់មួយជំនាន់ទៀត រយៈពេលគឺច្រើនជាង១២៥ឆ្នាំ អីចឹងយើងឃើញថាដោយសារតែគំនិតនេះហើយទើបខ្ញុំចាប់ផ្តើមរួមគ្នា ឥឡូវមានមនុស្សជាច្រើនចាប់ផ្តើមសរសេរព្រះគម្ពីរដោយដៃ ហើយខ្ញុំជឿថាជាព្រះគម្ពីរដែលធំបំផុតនៅក្នុងស្រុកខ្មែរ ហើយមានមនុស្សរាប់ពាន់នាក់ក្នុងការចូលរួមសរសេរ។

**អ្នកនាំសារ៖** ចុះប្រសិនបើមានខុសអក្សរតើសមាគមមានបញ្ហាអ្វីខ្លះដែរ?

**លោកហេង ពិសិដ្ឋ៖** យើងមានដំណាក់កាលនៃការសរសេរ មិនមែនមានន័យថាយើងចាប់ផ្តើមភ្លាមសរសេរភ្លាមនោះទេ។ ក្នុងសៀវភៅវាមានដាក់បន្ទាត់ច្បាស់លាស់ អីចឹងគាត់ត្រូវហ្វឹកហាត់សរសេរសិន ឧទាហរណ៍ថា យ៉ូហាន៣,១៦សរសេរក្នុងគម្ពីរនឹងត្រឹមតែ៤បន្ទាត់ទេ អីចឹងគាត់ត្រូវសរសេរត្រឹម៤បន្ទាត់ដែរ ប្រសិនបើគាត់សរសេរលើស៤បន្ទាត់គាត់ត្រូវហ្វឹកហាត់សរសេរម្តងទៀតដើម្បីឲ្យបាន៤ន្ទាត់។ ប៉ុន្តែយើងទុកបន្ទាត់ទំនេរមួយទៀតសម្រាប់អ្នកដែលសរសេរអក្សរធំ ប៉ុន្តែបើខុសយើងមានគោលការណ៍ បើខុសតែមួយតួដូចជាស្រៈ "េ"យើងអាចលុបបាន តែប្រសិនបើមួយពាក្យយើងមិនអាចលុបបានទេយើងត្រូវធូត។ អីចឹងហើយបានយើងទាមទារឲ្យមានការហ្វឹកហាត់សរសេរសិនហើយចាំគាត់មកសរសេរ។

**អ្នកនាំសារ៖** នៅក្នុងការសរសេរគម្ពីរ តើគាត់អាចយកគម្ពីរទៅសរសេរបាន ឬត្រូវមកសមាគមគម្ពីរដើម្បីសរសេរ?

**លោកហេង ពិសិដ្ឋ៖** ជាចាំបាច់ដោយសារតែព្រះគម្ពីរអត់ទាន់ចងក្រងជាសៀវភៅនៅឡើយទេ មានន័យថា នៅជាក្រដាសមួយសន្លឹកៗ អីចឹងប្រសិនបើយើងឲ្យគាត់យកទៅវាអាចជួបហានិភ័យនៃការបាត់បង់ដូចជាខូច ឬទទឹកទឹកភ្លៀង យើងការពារណាស់។អីចឹងយើងសុំប្រសិនបើគាត់ជាបុគ្គលទេ យើងសុំឲ្យគាត់មកសមាគមគម្ពីរ ដោយយើងមានបុគ្គលិកយើងជាជំនួយនៅនឹងស្រាប់។ ជួនកាលគាត់មានគ្នា៤ទៅ១០នាក់ជាក្រុមគាត់សរសេរទៅ ប៉ុន្តែដូចក្រុមជំនុំវិញ គាត់ត្រូវការគម្ពីរ១កាន់សៀវភៅ អីចឹងយើងឲ្យគាត់បញ្ជូនគ្នាគាត់៥ទៅ៦នាក់មកហ្វឹកហាត់ដើម្បីជួយអ្នកដ៏ទៃហើយបុគ្គលិកយើងនឹងជួយបង្រៀនគាត់ពីរបៀបសរសេរតែបុគ្គលិកយើងក៏ទៅជាមួយដែរដោយសារពេលសរសេរនឹងគឺសរសេរនៅក្នុងវិហារ ដោយឲ្យពួកគាត់ហ្វឹកហាត់សរសេរលើក្រដាសព្រាងក្រោយពេលហ្វឹកហាត់រួចរាល់ហើយមកចាប់ផ្តើមការសរសេរតែម្តង។

**អ្នកនាំសារ៖** តើគម្រោងនេះនឹងត្រូវបញ្ចប់នៅកំឡុងពេលណាមួយដែរឬមួយរងចាំសរសេរដល់មានអ្នកសរសេរគ្រប់គ្នាឬយ៉ាងម៉េច?

**លោកហេង ពិសិដ្ឋ៖** សម្រាប់គម្រោងមួយនេះយើងអត់កំណត់ពេលវេលាទេ ព្រោះយើងអត់ដឹងថាចប់ពេលណានោះទេ ប៉ុន្តែប្រសិនបើចប់ឆ្នាំនឹង រឹតតែសប្បាយចិត្តព្រោះខ្ញុំចង់ឃើញជាស្នាដៃមួយនឹងចង់អបអរ តែខ្ញុំអត់ដឹងថា ២ឬ៣ឬ៥ឆ្នាំទៀត ខ្ញុំអត់ដឹង។ [....]ទាក់ទងនឹងការសេរនេះ យើងក៏សុំឲ្យគាត់ដាក់ជង្វាយដែរ មានន័យថាក្នុង១ខ ប្រសិនបើគាត់ជាសមាជិកក្រុមជំនុំសុំគាត់ដាក់១ដុល្លាដើម្បីយើងចងក្រងជាសៀវភៅឬបើសេសសល់យើងទុកយកលុយទៅទិញគម្ពីរចែកជូនអ្នកខ្វះខាតទៀត នេះជាឱកាសមួយដើម្បីថាផ្តល់ពរដល់អ្នកដទៃ។

**អ្នកនាំសារ៖** តើសមាគមព្រះគម្ពីរនឹងមានគម្រោងអ្វីបន្តទៀតទេបន្ទាប់ពីបញ្ចប់សៀវភៅនេះ?

**លោកហេង ពិសិដ្ឋ៖** យើងនឹងមានគម្រោងបន្តទៀត ប្រសិនបើពួកជំនុំគាត់បានសរសេរចប់។ សមាគមគម្ពីរហ្វីលីពីនគេបានចងក្រងជាសៀវភៅមួយជាទម្រង់ដើម រួចស្តេនចូលទៅក្នុងកុំព្យូទ័រ ក្រោយមកគាត់បានបោះពុម្ពហើយលក់បន្តទៅកាន់អ្នកដែលចង់បានហើយអ្នកខ្លះគេចង់បានជាស្នាដៃរបស់គេហើយនេះជាអ្វីដែលយើងនឹងបន្តទៀតជាមួយនឹងសៀវភៅនេះ ហើយនៅទីណាដែលមានសិក្ខាសិលាតូចធំយើងនឹងយកសៀវភៅនេះទៅដាក់តាំងដើម្បីឲ្យគាត់ឃើញដែរថា នេះជាស្នាដៃខ្មែរសុទ្ធ៕

*ដោយ កញ្ញា*

# តើចិនកំពុងតែព្យាយាមធ្វើបងធំគ្រប់វិស័យនៅក្នុងតំបន់ឬយ៉ាងណា ?

ខណៈដែលចិនបានសម្រេចនូវសមិទ្ធិផលធំៗជាច្រើនរបស់ខ្លួនទាំងផ្នែកសេដ្ឋកិច្ច យោធា និងនយោបាយការបរទេសរបស់ខ្លួនជាបន្តបន្ទាប់មកនោះ ចិនត្រូវបានមតិមួយចំនួនអះអាងថា ប្រទេសមហាយក្សមួយនេះ កំពុងតែចង់ព្យាយាមធ្វើបងធំលើគ្រប់វិស័យនៅក្នុងតំបន់។

កាលពីប៉ុន្មានទសវត្សន៍មុន អ្វីដែលគេបានឮបានដឹងបានយល់ពីចិន គឺត្រឹមតែថាចិនគឺជាប្រទេសដែលមានប្រជាពលរដ្ឋច្រើនជាងគេនៅលើពិភពលោក ចិនគឺជាប្រទេសកុម្មុយនីស្តបែប ម៉ៅនិយម ចិនគឺជាប្រទេសដែលកំពុងតែអភិវឌ្ឍន៍ និងក្រីក្រមួយនៅលើពិភពលោក ប៉ុន្តែនៅក្នុងទសវត្សរ៍នេះ ការយល់ដឹងទាំងនេះគឺត្រូវបានគេមើលរំលងហើយ ដោយសារតែពេលនេះ ចិនគឺសឹងតែមានអ្វីៗទាំងអស់។

ក្រៅតែពីនៅរក្សាបាននូវឯកភាពទឹកដីនៅក្នុងចំណោមជាប្រទេសដែលមានទឹកដីធំជាងគេនៅក្នុងចំណោមប្រទេស ៥នៅលើពិភពលោក ដោយមានប្រជា ជនច្រើនជាងគេនៅលើពិភពលោក ពោលគឺជាង ១,៣ពាន់លាននាក់ ដដែល ហើយចិនបានដណ្តើមតួនាទីមួយថ្មីនៅលើពិភពលោក កាលពីប៉ុន្មានឆ្នាំមុននេះ គឺ ជាមហាអំណាចសេដ្ឋកិច្ចធំទីពីរ ខណៈដែលពីមុនតួនាទីនេះ គឺជារបស់ ប្រទេសជប៉ុន។

សព្វថ្ងៃនេះអត្រាផលិតផលសរុបរបស់ចិនជារួមគឺប្រមាណជា ២៥២៣៨ ទ្រីលានដុល្លារនៅក្នុងមួយឆ្នាំ គឺធំជាងជប៉ុន ដែលមានប្រមាណជា ត្រឹមតែ ៥១៦៧ ទ្រីលានដុល្លារនៅក្នុងមួយឆ្នាំ បើទោះបីជាអត្រាផលិតផលសរុបរបស់ប្រជាជនចិនម្នាក់ៗគឺនៅទាបជាងជប៉ុន ក៏ដោយចុះ ពោលគឺចិនត្រឹមតែ ១៨០០០ ដុល្លារនៅក្នុងមួយឆ្នាំ ខណៈដែលជប៉ុន គឺ ៤៤៤០០ដុល្លារនៅក្នុងមួយឆ្នាំឯណោះ ប៉ុន្តែគេដឹងថា ចិនកំពុងតែដណ្តើមកិត្យានុភាពច្រើនណាស់នៅលើពិភពលោក ជាពិសេសនៅក្នុងតំបន់អាស៊ាន។

នៅលើពិភពលោក នៅក្នុងឋានៈជាប្រទេសដែលមានទីផ្សារធំមានប្រជាពលរដ្ឋច្រើន ជាមហាអំណាច សេដ្ឋកិច្ចទីពីរនៅលើពិភពលោក ចិនដែលជាប្រទេសមួយកំពុងតែមានបញ្ហារឿងទឹកដីជាមួយនឹងកោះតៃវ៉ាននោះ បានដណ្តើមជោគជ័យផ្នែកការទូតជាច្រើនលើតៃវ៉ាន់ ដោយបណ្តាប្រទេសមួយចំនួន តូចនៅអាហ្វ្រិក ដែលធ្លាប់តែទទួលស្គាល់និងមានទំនាក់ទំនងការទូតជាមួយនឹងកោះតៃវ៉ាន់នោះ បានសម្រេចផ្តាច់ទំនាក់ទំនងការទូតជាបន្តបន្ទាប់ជាមួយនឹងកោះតៃវ៉ាន់ ហើយងាកមករកចាប់ដៃ ជាមួយនឹងប្រទេសចិន។ នៅក្នុងតំបន់អាស៊ាន ក៏ដូច្នេះដែរ បើទោះបីជានៅក្នុងចំណោមប្រជាពលរដ្ឋអាស៊ានតែងតែមានទស្សនៈមិនចូលចិត្តចិន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ចិនបានដណ្តើមនូវតួនាទីលេចធ្លោរជាច្រើននៅក្នុងតំបន់នេះ ដោយ មកដល់ពេលនេះចិនបានកំពុងតែបណ្តាក់ទុន និងពង្រីកឥទ្ធិពលសឹងតែគ្រប់វិស័យមកកាន់តំបន់អាស៊ានដែលគេដឹងថា គឺជាតំបន់ដែលមានទីតាំងភូមិសាស្ត្រជាអ្នកភូមិផងរបងជាមួយនឹងចិន។ ចិននៅពេលនេះ គឺជាដៃគូរពិភាក្សានិងសន្ទនាដ៏ចំបងមួយរបស់អាស៊ាន ដូចជាជប៉ុន ដូចជាកូរ៉េខាងត្បូងដែរ បើទោះបីជាប្រទេសមួយ ចំនួននៅអាស៊ាន កំពុងតែមានអរិយភាពនៃជម្លោះទឹកដី នៅសមុទ្រចិនខាងត្បូង និងរងសម្ពាធដោយសារតែការអភិវឌ្ឍន៍និងការធ្វើទំនើបកម្ម យោធាចិនដ៏សម្បើម ខណៈដែលសមត្ថភាពយោធារបស់អាស៊ាននៅមានកម្រិតក៏ដោយ។

ដោយឡែកលើវិស័យវិនិយោគនឹងសេដ្ឋកិច្ច ព្រមទាំងពាណិជ្ជកម្ម និងទេសចរណ៍ជាដើម មកដល់ពេលនេះ ប្រទេសទាំងឡាយនៅអាស៊ាន គឺសុទ្ធសឹងតែមានទំនាក់ទំនងដ៏ស្អិតល្មួត ព្រមទាំងទទួលឥទ្ធិពលពីចិន។ នៅក្នុងបណ្តាប្រទេសក្រីក្រនៅអាស៊ាន ដូចជា កម្ពុជា ឡាវ ភូមា វៀតណាមទុនវិនិយោគពីចិន គឺសុទ្ធតែឈរនៅលំដាប់កំពូល ខណៈដែលប្រទេសអាស៊ានផ្សេងទៀត ដូចជា ហ្វីលីពិន ថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី ជាដើមនោះ ក៏សុទ្ធតែស្ថិតនៅក្នុងលំដាប់កំពូលទាំង១០ដែរ។ នេះ គឺជាការសបញ្ជាក់អំពីតួនាទីដ៏រឹងមាំមួយរបស់ចិន។

ថ្មីៗនេះ ក្រៅពីបង្ហាញនូវឥទ្ធិពលនៃសេដ្ឋកិច្ច យោធាន យោបាយការទូត និងសេដ្ឋកិច្ចនៅក្នុងតំបន់ និងនៅលើពិភពលោក ហើយនោះ ចិនក៏នៅតែបន្តជំរុញតួនាទី និងឥទ្ធិពលមកកាន់តំបន់ អាស៊ាននេះបន្ថែមទៀត ដោយចិនកំពុងតែពង្រីកនូវឥទ្ធិពលលើវិស័យព័ត៌មានផងដែរ។ ជាក់ស្តែង កាលពីដើមខែកក្កដាកន្លងទៅនេះ កាសែតប្រជាជនប្រចាំថ្ងៃចិន គឺ People Daily បានចំណាយថវិការមិនជា តិចនោះទេនៅក្នុងការរៀបចំ កិច្ចប្រជុំកំពូលនៃប្រព័ន្ធផ្សព្វផ្សាយមេគង្គ-ឡានឆាង នៅក្នុងទីក្រុង វៀងច័ន្ទ រដ្ឋធានីនៃប្រទេសឡាវបន្ទាប់ពីចិនខ្លួនឯងបានរៀបចំដោយជោគជ័យកាលពីឆ្នាំ២០១៧ នៅប្រទេសចិនរួចហើយនោះ។

នាកិច្ចប្រជុំកំពូលនៃប្រព័ន្ធផ្សព្វផ្សាយមេគង្គ-ឡានឆាង នៅក្នុងប្រទេសឡាវនេះ បណ្តាអ្នកដឹកនាំ និងអ្នកកាសែតមកពីអង្គភាពកាសែត និងប្រព័ន្ធផ្សព្វផ្សាយធំៗ និងល្បីៗនៅប្រទេសចិន កម្ពុជា វៀតណាម ឡាវ ថៃ និងភូមា សុទ្ធតែបានបង្ហាញមុខនឹងចូលរួម។ ជុំវិញការចូលរូមនេះ មានទស្សនៈមួយ ចំនួនបានលេចឡើង ដោយសារតែគឺជារឿងថ្មី ដែលប្រព័ន្ធផ្សព្វផ្សាយរដ្ឋដ៏ធំមួយរបស់ចិន បានសុខចិត្តចំណាយថវិការាប់សិបម៉ឺនដុល្លារ នៅក្នុងការចំណាយរៀបចំកិច្ចប្រជុំមួយនេះឡើយ ដោយឧបត្ថម្ភតាំងពីថ្លៃស្នាក់នៅ ថ្លៃធ្វើដំណើរ ថ្លៃហូបចុក សម្រាប់អ្នកកាសែត និងអ្នកចូលរួមប្រមាណជាជាង ១០០ នាក់នោះ។ អ្វីទៅនៅពីក្រោយគំនិតផ្តួចផ្តើមនេះ? តើហេតុអ្វីបានជាចិនរៀបចំព្រឹត្តិការណ៍នេះឡើង។ បើរៀបចំនៅចិន គេអាចយល់បានថា ជាការជម្រុញការផ្សព្វផ្សាយ និង ធ្វើទីផ្សារឃោសនា ពីប្រទេសចិន ហើយនេះជាទម្លាប់ដែលប្រទេសណាក៏បានធ្វើដែរ ជាពិសេសប្រទេសដែល មានលទ្ធភាព តាមការអញ្ជើញទស្សនកិច្ចផ្សព្វផ្សាយនេះ ប៉ុន្តែនេះ គឺជាកិច្ចប្រជុំកំពូលនៅ វៀងច័ន្ទ គឺនៅក្រៅពីប្រទេសចិន។

នេះគឺជាសំណួរ ដែលមតិសាធារណជនមួយចំនួន បានរំលេចឡើង ប៉ុន្តែទោះបី ជាយ៉ាងណាក៏ដោយ នៅក្នុងទស្សនៈជាកោសិកានៃប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មានមួយនៅក្នុងប្រទេសកម្ពុជា យើងខ្ញុំគិតថា ទោះបីជាយ៉ាងណាក៏ដោយ ក៏វាជាបច្ច័យមួយនិងជាឱកាសមួយ ដ៏ប្រសើរដែលអ្នកសារព័ត៌មាន នៅក្នុងតំបន់ អាចមានឱកាសជួបគ្នាពិភាក្សា។ ការជួប និងការនិយាយពិភាក្សាគ្នានេះ គឺជាការបង្កើនឱកាសនៃការយល់ដឹងពីគ្នា កាន់តែច្បាស់ទៅវិញទៅមកដើម្បីរកផ្លូវឈានទៅរកការពង្រឹងនូវកិច្ចសហប្រតិបត្តិការថ្មីៗណាមួយផ្សេងទៀត។ ចិន ជាមហាអំណាចមួយ និងជាទីផ្សារដ៏ធំនៅលើពិភពលោកមួយស្រាប់ដូច្នេះ ប្រសិនបើប្រទេសនៅក្នុងតំបន់អាចរកគន្លឹះណាមួយ ដើម្បីបង្កើនទំនុកចិត្ត តាមរយៈយន្តការផ្សេងៗ ដោយរួមទាំងប្រកអាស៊ានក្តី ប្រកកិច្ចប្រជុំកំពូលនៃប្រព័ន្ធផ្សព្វផ្សាយមេគង្គ-ឡានឆាងក្តី ដោយឈរនៅលើយុទ្ធសាស្ត្រឈ្នះ ឈ្នះទាំងអស់គ្នាផលប្រយោជន៍ទៅវិញទៅមកនោះ គឺជារឿងមួយដ៏ប្រសើរ៕

*ដោយ អរិយបុត្រ*



ថតដោយ: AKP

# កម្ពុជានឹងមានគោលនយោបាយជំឡូងមី សម្រាប់ទីផ្សារពិភពលោក

រដ្ឋមន្ត្រីនៃក្រសួងពាណិជ្ជកម្ម លោក ប៉ាន សូរស័ក្តិ បានបង្ហាញជំនឿថា ឯកសារគោលនយោបាយនឹងប្រែក្លាយកម្ពុជា ឲ្យទៅជាទីតាំងឧស្សាហកម្មកែច្នៃ និងផ្គត់ផ្គង់ជំឡូងមីដែលអាចជឿទុកចិត្តបានសម្រាប់ទីផ្សារពិភពលោក។ ដោយសារឯកសារនេះ ផ្តល់នូវចក្ខុវិស័យច្បាស់លាស់និងវិធីសាស្ត្ររៀបចំខ្សែសង្វាក់តម្លៃសំខាន់ៗ ដើម្បីធ្វើឲ្យដំណាំជំឡូងមី ទទួលបានទិន្នផលច្រើន និងមានតម្លៃខ្ពស់ អាចឆ្លើយតបតម្រូវការនៃទីផ្សារទាំងក្នុង និងក្រៅប្រទេស។ លោកបានបង្ហាញជំនឿចិត្តដូចនេះ នាឱកាសអញ្ជើញជាអធិបតីភាពក្នុងពិធីប្រគល់ និងទទួលឯកសារគោលនយោបាយជំឡូងមី ដែលរៀបចំឡើងនៅទីស្តីការក្រសួងពាណិជ្ជកម្ម កាលពីព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ក្រោមការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការមកពីអន្តរក្រសួង តំណាងវិស័យឯកជន និងអង្គការUNDPដែលជាសមាជិក សមាជិកានៃគណៈកម្មការរៀបចំគោលនយោបាយជាតិជំឡូងមីប្រមាណជាង ៥០នាក់។

ក្នុងនោះ ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងអំណរគុណ ដល់នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម ដែលបានប្រឹងប្រែងសហការជាមួយអង្គការ UNDP និងស្ថាប័នពាក់ព័ន្ធធ្វើការចងក្រងឯកសារដ៏មានសារៈសំខាន់នេះឡើង ដើម្បីបម្រើការអភិវឌ្ឍវិស័យជំឡូងមីកម្ពុជា ដែលជាដំណាំសក្តានុពលទី២ បន្ទាប់ពីដំណាំស្រូវ និងជាផលិតផលអាហារប្រចាំសតវត្សរ៍ទី២១។ លោកបណ្ឌិត រឺឆាត ម៉ាស្តូល សេដ្ឋវិទូនៃអង្គការ UNDP ប្រចាំប្រទេសកម្ពុជា បានគូសបញ្ជាក់ថា គោលនយោបាយជំឡូងមីនឹងប្រែក្លាយជំឡូងមីទៅជាដំណាំដែលផ្តល់ទិន្នផល និងប្រាក់ចំណូលខ្ពស់សម្រាប់ប្រជាកសិករក្រីក្រ និងជាផលិតផលដែលបម្រើការអភិវឌ្ឍឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជា។ លោកបណ្ឌិតបានបន្តទៀតថា ដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្តគោលនយោបាយ រចនាសម្ព័ន្ធអភិបាលកិច្ចត្រូវបានបង្កើតឡើង ហើយខ្សែសង្វាក់តម្លៃជំឡូងមី ត្រូវបានបែងចែកជាផ្នែកៗ ដើម្បីតភ្ជាប់ជាមួយវិស័យអាទិភាពផ្សេងទៀត។ សូមជម្រាបថាកាលពីឆ្នាំ២០១៧ កម្ពុជាបានក្លាយជាប្រទេសដែលឈរនៅលំដាប់លេខរៀងទី៨ ក្នុងចំណោមប្រទេសផលិតជំឡូងមីធំៗទាំង១០នៅលើពិភពលោក។ ចាប់តាំងពីឆ្នាំ២០១១ ផ្ទៃដីដាំដុះជំឡូងមី ត្រូវបានពង្រីកពី៤០០ពាន់ហិកតាដល់ ៥៧៤ពាន់ហិកតានៅក្នុងឆ្នាំ២០១៥ ហើយបានផ្តល់ទិន្នផលសរុបជាង១៣លានតោន។ កន្លងមកយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម(CTIS) បានដាក់បញ្ចូលដំណាំជំឡូងមី ទៅជាផលិតផលអាទិភាពមួយ ដើម្បីអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ និងធ្វើពិពិធកម្មការនាំចេញ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាណិជ្ជកម្ម បានកំពុងប្រឹងប្រែងជំរុញការនាំចេញផលិតផលជំឡូងមី៕

# ក្រុមលោកអភិបាលកាតូលិកនៅហ្វីលីពីន អំពាវនាវឲ្យគ្រីស្តបរិស័ទ អធិដ្ឋាន និងតមអាហារបន្ទាប់ពីការប្រមាថ របស់លោក Duterte

ក្រុមសភាលោកអភិបាលព្រះសហគមន៍កាតូលិកហ្វីលីពីនបានអំពាវនាវឱ្យមានការអធិស្ឋានរយៈពេលបីថ្ងៃ និងតមអាហារប្រហែលមួយខែបន្ទាប់ពីលោកប្រធានាធិបតី Rodrigo Duterte បានហៅព្រះជាម្ចាស់ថា"ល្ងង់"។

បន្ទាប់ពីមានប្រតិកម្ម ចំពោះការនិយាយបែបនេះរបស់ប្រធានាធិបតីក្រុមសភាលោកអភិបាលព្រះសហគមន៍ប្រទេសនេះបានជួបជាមួយលោក Duterte ដើម្បីព្យាយាមបន្ធូរបន្ថយភាពតានតឹង។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មានកាតូលិក CNA នាថ្ងៃទី៩ ខែកក្កដា។

ការដែលលោកប្រធានាធិបតីនិយាយថា ព្រះជាម្ចាស់ "ល្ងង់" បានទទួលរងនូវប្រតិកម្មទាំងកំហឹងផងពីសំណាក់ប្រជាជនដែលប្រទេសនេះមានអ្នកកាន់សាសនាកាតូលិកភាគច្រើន។

លោកអភិបាល រ៉ូមូឡូ វ៉ាលឡេស នៃភូមិភាគដាវ៉ៅ ជាប្រធានសភាលោកអភិបាលកាតូលិកហ្វីលីពីន (CBCP)បានសរសេរលិខិតផ្លូវការមួយអំពាវនាវចំពោះប្រជាជនហ្វីលីពីនដោយកំណត់យកថ្ងៃទី ១៦ កក្កដា ជាថ្ងៃនៃការអធិស្ឋាន និងការបន់ស្រន់សុំសេចក្តីមេត្តាករុណានិងយុត្តិធម៌សម្រាប់"អ្នកដែលបានប្រមាថដល់ព្រះជាម្ចាស់ជានាមដ៏វិសុទ្ធ។ ហើយអង្វរសម្រាប់ពួកអ្នកដែលបង្ខាច់បង្ខូចនិងធ្វើជាសាក្សីក្លែងក្លាយ និងអ្នកដែលប្រព្រឹត្តឃាតកម្ម ឬបង្ហាញពីឃាតកម្មជាមធ្យោបាយសម្រាប់ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនៅក្នុងប្រទេសរបស់យើង"។

ក្រុមលោកអភិបាល បានកំណត់យករយៈពេល៣ថ្ងៃបន្ទាប់ គឺចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ១៩ខែកក្កដា ជាថ្ងៃនៃការតមអាហារ ការអធិស្ឋាន និងការធ្វើទាន។

សារលិខិតដាស់តឿនមានចំណងជើងថា "អំណរសប្បាយ និងការត្រេកអរ" ត្រូវបានចេញផ្សាយដោយ CBCP កាលពីថ្ងៃទី ៩ ខែកក្កដា។

ទោះបីជាវាមិនបានបញ្ជាក់ច្បាស់ពីឈ្មោះលោក Duterteក៏ដោយក៏ក្នុងសារលិខិតបានបង្ហាញពីសកម្មភាពនិងគោលនយោបាយមួយចំនួនរបស់លោកប្រធានាធិបតីកន្លងមក រួមទាំង "អ្នកដែលក្រអឺតក្រទមចាត់ទុកខ្លួនឯងថាមានប្រាជ្ញានៅក្នុងការប៉ាន់ស្មានផ្ទាល់ខ្លួន ចោទថាជំនឿរបស់គ្រីស្តបរិស័ទមិនសមហេតុសមផល" ក៏ដូចជា "អ្នកដែលប្រមាថដល់ព្រះជាម្ចាស់របស់យើងថាល្ងង់"។

ចាប់តាំងពីជាប់ការបោះឆ្នោត លោកDuterte ត្រូវបានគេចោទប្រកាន់ពីបទ "បោសសម្អាតសង្គម" ជាមួយនឹងសង្គ្រាមហិង្សារបស់គាត់លើក្រុមគ្រឿងញៀន។ ព្រះសហគមន៍បានប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ប្រឆាំងនឹងគោលនយោបាយទាំងនេះ។

ក្នុងលិខិតនោះបញ្ជាក់ថា "យើងមិនមែនជាមេដឹកនាំនយោបាយទេ ហើយមិនមែនជាគូប្រជែងនយោបាយរបស់រដ្ឋាភិបាលដែរ"។ កន្លងទៅព្រះសហគមន៍បានធ្វើការជាមួយរដ្ឋាភិបាលដើម្បីប្រយោជន៍រួមក្នុងការជួយដល់អ្នកក្រីក្រនិងអ្នកខ្សត់ខ្សោយ។

លោកVallesនិយាយថា"ចំពោះបញ្ហាជាក់ស្តែងខ្លះ ការសហការអាចមិនអាចទៅរួចទេដោយសារជំនឿខាងផ្លូវវិញ្ញាណ និងសីលធម៌របស់យើង។ យើងស្នើជាបន្តបន្ទាប់ ប៉ុន្តែមិនតម្រូវតាមការមិនចង់បាននោះទេ"។ ក្នុងករណីបែបនេះយើងអាចគ្រាន់តែលើកឡើងពីសិទ្ធិរបស់យើងចំពោះការជំទាស់តាមមនសិការ។"

លិខិតនេះបន្តថា ព្រះសហគមន៍គ្មាន"របៀបវារៈនយោបាយ ឬមនោគមវិជ្ជាណាមួយនៅក្នុងចិត្តឡើយ" ហើយនៅពេលក្រុមលោកអភិបាលដោះស្រាយបញ្ហា "វាតែងតែកើតឡើងពីទស្សនវិស័យនៃជំនឿ និងសីលធម៌ ជាពិសេសគោលការណ៍នៃយុត្តិធម៌សង្គម"។

សារលិខិតបានបញ្ជាក់ផងដែរអំពីការដោះស្រាយអំពើហិង្សានៅក្នុងប្រទេស។ បូជាចារ្យបីនាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសហ្វីលីពីនក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះ ជាមូលហេតុបំផុសគំនិតបូជាចារ្យជិត២០០នាក់ បានស្នើសុំលិខិតអនុញ្ញាតកាន់កាំភ្លើង។ CBCP គឺមិនគាំទ្រដល់លោបូជាចារ្យកាន់អាវុធទេ សូម្បីតែស្របច្បាប់ក៏ដោយ។ ប៉ុន្តែ លោកអភិបាលត្រូវតែផ្តល់ការអនុញ្ញាតដល់បូជាចារ្យនៅក្នុងភូមិភាគរបស់គាត់ឲ្យកាន់កាំភ្លើង។

គំនិតនៃ "ពួកបូជាចារ្យដែលត្រូវគេធ្វើឃាតដើម្បីធ្វើជាសាក្សីដល់ព្រះគ្រីស្ត" មិនមែនជារឿងថ្មីទេ។ គាត់បានលើកទឹកចិត្តប្រជាជនហ្វីលីពីនឱ្យចងចាំពាក្យសម្តីរបស់លោកប៉ូលក្នុងលិខិតដំបូងរបស់គាត់ទៅកាន់គ្រីស្តបរិស័ទក្រុងកូរិនថូស ត្រូវ"ឆ្លើយតបដោយជូនពរ" ដល់អ្នកប្រមាថ និងឆ្លើយតប"ដោយទន់ភ្លន់"ទៅអ្នកបង្ខាច់បង្ខូច។

លោក Valles ក៏បានថ្កោលទោសចំពោះស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ប្រទេសនេះ ដោយនិយាយថាការឃុំឃាំងមានភាពចង្អៀតខ្លាំងចំពោះអ្នកដែលត្រូវបានចាប់ខ្លួនពីបទជួញដូរថ្នាំញៀន និងអ្នកដែលគួរតែត្រូវបានស្តារនីតិសម្បទា ហើយថាប្រជាជនបានដកខ្លួនចេញឆ្ងាយពីអ្នកក្រ អ្នកជម្ងឺ និងអ្នកញៀនថ្នាំទាំងនោះ។

លោកបានសរសេរថា "យើងមានពាក្យមួយនៅក្នុងភាសា Tagalog ថា" ការឈឺចាប់ផ្នែកមួយនៃរាងកាយត្រូវបានទទួលអារម្មណ៍ដោយរាងកាយទាំងមូល "។

"Alas, ពាក្យនេះមិនមែនជាការពិតរហូតទេ! គ្មានផ្លូវដែលយើងអាចមានអារម្មណ៍ឈឺចាប់នោះទេ ល្គឹកណាផ្នែកខ្លះនៃរាងកាយត្រូវបានគេធ្វើបាបដោយការព្រងើយកន្តើយ"៕

# ក្រោយការបោះឆ្នោតពលរដ្ឋទីក្រុងចង់បានប្រព័ន្ធលូ យុត្តិធម៌សង្គម និងការអភិវឌ្ឍ



ប្រជាពលរដ្ឋកម្ពុជាមួយចំនួនដែលជាអ្នកនៅក្នុងចំណោមប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតចំនួនជាង ៨លាននាក់ បានបញ្ចេញយោបល់និងបំណងប្រាថ្នារបស់ពួកគេផ្សេងៗគ្នា ក្រោយពេល បោះឆ្នោត ប៉ុន្តែជារួមគឺថា អ្នកដែលនៅទីក្រុងពិសេសគឺនៅរាជធានីតែម្តង គឺពួកគេចង់បានប្រព័ន្ធលូ និងចរាចរណ៍មួយ ដែលប្រសើរ ខណៈដែលបងប្អូននៅជនបទ គឺកំពុងតែស្រេកឃ្លានយុត្តិធម៌សង្គម និងការអភិវឌ្ឍមូលដ្ឋានរបស់ពួកគេតែម្តង។

សកម្មជនគណបក្សប្រជាជនកម្ពុជាមួយរូប ដែលសុំមិនបញ្ចេញឈ្មោះ បានមានប្រសាសន៍នៅក្នុង អំឡុងពេល នៃយុទ្ធនាការឃោសនាបោះឆ្នោត ពោលគឺក្រោយពេលដែលគណបក្សនេះបានប្រកាសបើកយុទ្ធនាការ នៅកោះពេជ្រ កាលពីថ្ងៃទី០៧ ខែកក្កដា ថា សម្រាប់លោកដែល ជាអ្នករស់នៅរាជធានីភ្នំពេញនេះ ដូចជាមានអ្វីគ្រប់យ៉ាងដែរហើយ គ្រាន់តែចង់បានបន្ថែមរឿងលូ និងរឿងចរាចរណ៍ និងសណ្តាប់ធ្នាប់បន្តិច ។

លោកបានបញ្ជាក់ថា "រឿងអភិវឌ្ឍអីដូចជាយើងមានដូចគេដូចឯង ដូចប្រទេសជិតខាងដែរ តែយើង វាចេះតែលិចពេលដែលមានភ្លៀងម្តងៗ ហើយចរាចរណ៍គឺយ៉ាប់ហ្មងឥឡូវ ដូច្នេះ បើបក្ស ឈ្នះឆ្នោត ខ្ញុំគិតថា គណបក្សដោះស្រាយបញ្ហានេះបាន គឺល្អហ្មង"។

លោក លឹម សុខហៀង ជាប្រជាពលរដ្ឋវ័យ៦២ ឆ្នាំ បានមានប្រសាសន៍ថា រឿងដែលចង់បាននោះ គឺវាមានច្រើនរហូតដេកនឹកប្រហែលជាមិនអស់ផង តែចំពោះមុខបើសិនគណបក្សណាឈ្នះឆ្នោត អាចដោះស្រាយរឿង ពេលភ្លៀងលិច និងរឿងសណ្តាប់ធ្នាប់ចរាចរណ៍នេះចេញ ប្រសើរមែនទែនតែម្តង ។

នៅក្នុងនាមជាប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញមួយរូប លោកបានបន្តថា និយាយឲ្យវាពិតទៅ នៅរាជធានីភ្នំពេញនេះបើគណបក្សណាឈ្នះឆ្នោតអាចធ្វើបានលើរឿងសន្តិសុខរឿងចោរ ឆក់ ចោរប្លន់ រឿងគ្រឿងញៀន រឿងបក្សរឿងពួកនៅក្នុងកន្លែងធ្វើការ... តែទោះយ៉ាងណា បើអាចដោះស្រាយបានលឿនៗនូវបញ្ហាទឹកលិច និងរឿងគ្រប់គ្រងចរាចរណ៍ឲ្យបានត្រឹមត្រូវ ការបើកបរមានច្បាប់ មានទម្លាប់ ចេះប្រកាន់ស្តាំ ឆ្វេងត្រឹមត្រូវ។

លោកបានបញ្ជាក់ថា "អារឿងមើលកាសែត មើលហ្វេសបុកឃើញរឿងចោរប្លន់ ចោរឆក់ វាមធ្យមទេ តែវាធំ រឿងឲ្យតែភ្លៀង ផ្ទះខ្ញុំដឹងតែលិចកន្លះផ្ទះហ្មង"។ លោកបានសង្កត់ធ្ងន់ទៀតថា រឿងចរាចរណ៍ក៏ជារឿងធំមួយដែរ។

លោកបានបញ្ជាក់ទៀតថា "នៅង៉ៃ (ថ្ងៃ) ណាមួយផ្ទុះ (គំហឹង) ហើយភ្លើងខៀវលោត ៣ទៅ ៤ដងហើយ ចរាចរណ៍អត់កម្រើកសោះ មិនដឹងស្ទះអី តែដល់ទៅបានទៅបានឃើញ ស្ទះមកអាឡានខ្លះ វាបទចុះបទឡើងចូលចតស៊ីបាយ"។

សកម្មជនវ័យ ២៦ ឆ្នាំរបស់គណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យ និងជាម្ចាស់សន្លឹកឆ្នោតមួយរូបដែរនោះ បានឲ្យដឹងថា ប្រទេសកម្ពុជាពិតជាអភិវឌ្ឍន៍លឿនមែន ប៉ុន្តែការអភិវឌ្ឍន៍នោះ មិនដឹងយ៉ាងម៉េចទេ។ វាដូចជាឆកល្វែងរឿងរៀបចំលូរៀបចំរឿងសណ្តាប់ធ្នាប់តែម្តង ។

លោកបានបន្តថា ជាង៤ទៅ៥ ឆ្នាំ

# និងចរាចរណ៍ប្រសើរ តែអ្នកនៅជនបទចង់បាន


ផតដោយ: លី សុវណ្ណា

ដែលលោកបានមកស្នាក់នៅ និងរៀនបន្ត នៅរាជធានីភ្នំពេញនេះ គឺបញ្ហាវាដូចជានៅដដែលៗ គឺអារឿងទឹកលិច រឿងលូ រឿងសណ្ដាប់ធ្នាប់អារឿងចរាចរណ៍ រឿងគ្រឿងញៀន ។

យុវជន ដែលមកពីខេត្តបាត់ដំបងរូបនេះ បានបញ្ជាក់ថា "កាលមកភ្នំពេញដំបូងខ្ញុំជួលផ្ទះគេនៅម្តុំ ទួលសង្កែ ទឹកលិចដល់ក្រោយមករើទៅនៅម្តុំទួលគោក នៅតែលិច ហើយឥឡូវនេះ នៅម្តុំវត្តសន្សំកុសល គឺនៅតែលិច ហើយបើចរាចរណ៍វិញ និយាយលែងចេញតែម្តង ជាពិសេសនៅម្តុំផ្សារ នៅតាមហាង តាមកន្លែងមានភោជនីយដ្ឋានច្រើន"។

យុវជនរូបនោះបានបញ្ជាក់ថា "តាំងពីមកនៅភ្នំពេញនឹងគេមក ដូចជាអត់ដែលបាននៅកន្លែងណា ដែលមិនលិចទឹកទេ នៅរដូវភ្លៀង"។

លោក ជិន ពិសិដ្ឋ ជាប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញមួយរូប បានឲ្យដឹងថា រឿងសំរាមក៏ជារឿងដែលមិនអាចមើលរំលងបានដែរ។

លោកបានបន្តថា ម្នាក់ៗនិយាយអំពីចរាចរណ៍ និយាយអំពីរឿងទឹកលិច ប៉ុន្តែរឿងសំរាមក៏គួរតែលើកឡើងដែរ ហើយសង្ឃឹមថា គណបក្សណាឈ្នះឆ្នោតនឹងដោះស្រាយរឿងសំរាមនេះឲ្យបានផងដែរ។

លោកបានបន្តថា មន្ត្រីណាក៏ដូចជាមន្ត្រីណាដែរ ពេលនិយាយរឿងទឹកលិចគេថា មកពីសំរាម ពលរដ្ឋទុកដាក់សំរាមមិនល្អ បណ្តាលឲ្យហូរចូលទៅក្នុងប្រព័ន្ធលូ ធ្វើឲ្យលូស្ទះ ហើយអ្នកខ្លះពេល ស្ទះមួយចំនួន ក៏ស្តីបន្ទោសទៅលើឡានដឹកសំរាម ដោយសារផ្លូវវាតូច ដល់ពួកគាត់បើកឡានប្រមូលសំរាមយឺតៗ ស្ទះ ដូច្នេះ ប្រសិនបើក្រោយពេលបោះឆ្នោត អ្នកណាដោះស្រាយរឿងនេះបានល្អណាស់។

លោកបានបញ្ជាក់ថា "ខ្ញុំគាំទ្រពេញទំហឹងហ្មងរឿងសំរាមនេះ គួរតែប្រមូលពេលយប់ មិនគួរពេលម៉ោងពេលចេញទៅធ្វើការទេ ហើយប្រមូលទៀតសោតគួរតែមួយថ្ងៃម្តង មិនមែនកន្លែងខ្លះចង់ កន្លះខែបានមកយកម្តងឡើយ"។

លោក រិន ពន្លក ដែលជាអាជីវកម្មយរូបមានទីលំនៅនៅក្រុងកំពង់ចាម បានចូលរួមបញ្ចេញយោបល់ថា គណបក្សដែលជាប់ឆ្នោតពេលមានសភា មានរដ្ឋាភិបាលត្រឹមត្រូវគួរតែយកចិត្តទុកដាក់ លើរឿងយុត្តិធម៌សង្គមនិងការអភិវឌ្ឍបន្ថែមទៀត។

លោកបានបន្តថា រឿងអភិវឌ្ឍន៍ គឺរាជរដ្ឋាភិបាលកន្លងមក ៥ អណត្តិមុន គឺបានធ្វើច្រើនហើយ គឺដូចជា ផ្លូវ ស្ពាន ប៉ុន្តែទោះបីជាយ៉ាងណា គឺនៅមិនទាន់គ្រប់ទេ គួរតែយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសគឺនៅតាមតំបន់ជនបទ ដូចជារឿងទឹកស្អាត ភ្លើងអគ្គិសនី រឿងទីផ្សារកសិផលជាដើម ឯរឿងសង្គមវិញនោះ គួរតែយកចិត្តទុកដាក់បន្ថែមទៀតទៅលើយុត្តិធម៌សង្គម ។

លោកបានបញ្ជាក់ថា "អភិវឌ្ឍន៍នោះគឺអភិវឌ្ឍន៍ហើយ ប៉ុន្តែបើសិនជាអ្នកក្រចេះតែក្តីមិនឈ្នះអ្នកមាននោះ ក៏គួរតែសិក្សានិងពង្រឹងប្រព័ន្ធយុត្តិធម៌ឡើងវិញដែរ"។

លោកបានបន្តទៀតថា រឿងយុត្តិធម៌សង្គមនេះ សំខាន់ណាស់ ពីព្រោះបច្ចុប្បន្ននេះ នរណាក៏និយាយ និងត្អូញត្អែរអំពីយុត្តិធម៌សង្គមនៅក្នុងសង្គមយើងនាពេលបច្ចុប្បន្ននេះដែរ។ លោកបាន បន្តថា រឿងនោះមានច្រើនណាស់ តាំងពីរឿងដីធ្លី រឿងរំលោភនេះរំលោភនោះ ព្រមទាំងរឿងរ៉ាវផ្សេងៗ ប៉ុន្តែជាទូទៅ អ្នកតូចទាប អ្នកក្រីក្រ បើសិនជាគ្មានអន្តរាគមន៍ ពីអ្នកនេះអ្នកនោះ អ្នកនយោបាយទេ គឺពិបាករឿងយុត្តធម៌នេះតែម្តង ។

លោកស្រីសេក កញ្ញារ័ត្ន ដែលជាប្រជាពលរដ្ឋមួយរូបមកពីខេត្តកំពង់ឆ្នាំង បានឲ្យដឹងថា និយាយអំពីសមិទ្ធិផល គឺវាមានច្រើននៅភូមិស្រុក ដោយរួមទាំងសាលារៀន មន្ទីរពេទ្យ វត្តអារាម ផ្លូវ អគ្គិសនី គ្រាន់តែសេវាកម្មនោះ វារាងដូចជា យ៉ាប់បន្តិច។

លោកស្រីបានបញ្ជាក់ថា "សាលា និងពេទ្យឥឡូវនៅនឹងរបងផ្ទះ តែគ្រាន់តែដូចជាមិនសូវសេកម្ម បើពង្រឹងតែបន្តិចប្រសើរណាស់"។

លោក ស៊ុំ សាប្ញទ្ធិ ជាប្រជាពលរដ្ឋមួយរូប នៅស្រុក ស្ទឹងត្រង់ ខេត្តកំពង់ចាម បានអះអាង នៅស្តន់កន្លែងដែលឈប់ស៊ុំចត និងសម្រាកលំហែររបស់អ្នកដំណើរបានលើកជាយោបល់ថា ប្រសិនបើគណបក្សណាមួយឈ្នះឆ្នោត អាចជួយជាក្រុមអ្នកច្បាប់សម្រាប់ជួយអ្នកក្រីក្រ ដែលមានតម្រូវការ ច្បាប់ប្រហែលជាល្អបំផុត ។

លោកបានអះអាងថា "ប្រជាពលរដ្ឋឥឡូវពិតជាត្រូវការជំនួយ ផ្នែកច្បាប់ ផ្នែកក្តីក្តាំនេះមែន ពីព្រោះតែផលប្រយោជន៍គឺឧស្សាហ៍មានជម្លោះណាស់"៕

*ដោយ អរិយបុត្រ*

## គណបក្សចូលរួមការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អណត្តិទី ៦ មាន២០ គណបក្ស

តាមការអះអាងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានឲ្យដឹងថា គណបក្ស នយោបាយដែលបានចុះឈ្មោះចូលរួមការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅអណត្តិទី ៦ ចំនួន ១២៥ អសនៈនេះ គឺមាន ២០ គណបក្ស ។

ប្រភពដដែលបានបន្តថា ចំនួនអសនៈនៃតំណាងរាស្ត្រគឺមានការកើនឡើងពីរ គឺនៅមណ្ឌលខេត្ត ព្រះសីហនុមានការកើនឡើង២ អសនៈ។

គណបក្សទាំង២០ ដែលបានចុះឈ្មោះចូលរួមការបោះឆ្នោតនេះ គឺមានគណបក្សខ្លះមានបេក្ខភាព តំណាងរាស្ត្រមិនគ្រប់តាមមណ្ឌលនោះទេ ។

គណបក្សដែលចូលរួមការបោះឆ្នោតរួមមាន គណបក្សប្រជាជនកម្ពុជា, គណបក្សយុវជនកម្ពុជា, គណបក្សសញ្ជាតិកម្ពុជា, គណបក្សខ្មែររួបរួមជាតិ, គណបក្សហ្វ៊ុនស៊ិនប៉ិច, គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, គណបក្សប្រជាធិបតេយ្យមូលដ្ឋាន, គណបក្សពន្លឺថ្មី, គណបក្សខ្មែរតែមួយ, គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ, គណបក្សធម្មាធិបតេយ្យ, គណបក្សខ្មែរឈប់ក្រ, គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច, គណបក្សខ្មែរសាធារណរដ្ឋ, គណបក្សរស្មីខេមរា, គណបក្សឆន្ទៈខ្មែរ,គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ, គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា, គណបក្សមាតុភូមិយើង, និង គណបក្សខ្មែរក្រោក ៕

## សមាសភាពតំណាងរាស្ត្រអណត្តិចាស់

ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតអណត្តិទី ៥ នៅក្នុងសភាដែលមានអសនៈ ១២៣ គឺ ត្រូវបាន កាន់កាប់ ដោយគណបក្សប្រជាជនកម្ពុជាចំនួន ៦៨ អសនៈ និងគណបក្សសង្គ្រោះជាតិមាន ៥៥ អសនៈ ប៉ុន្តែក្រោយពេល គណបក្សនេះត្រូវបានរំលាយចោលដោយសាលក្រមតុលាការមក ចំនួនអសនៈ ទាំង ៥៥ របស់គណបក្សនេះ ត្រូវបានបែកចែកទៅឲ្យគណបក្សផ្សេងទៀត ។

នៅមុនពេលដែលរដ្ឋសភាត្រូវបានរំលាយសុពលភាព ដើម្បីរៀបចំការបោះឆ្នោតអណត្តិថ្មី អសនៈ ទាំង ១២៣ កន្លែង គឺត្រូវបានកាន់កាប់ ៧៩ អសនៈដោយគណបក្សប្រជាជនកម្ពុជា ៤១ អសនៈ ដោយគណបក្សហ្វ៊ុនស៊ុនប៉ិច ២ អសនៈ ដោយ គណបក្សសញ្ជាតិកម្ពុជា និង ១ អសនៈទៅ គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ៕

# អង្គការការីតាសកម្ពុជាផ្តល់ជំនាញដល់យុវនារីនិងស្ត្រីដើម្បីចិញ្ចឹមជីវិត

ក្នុងបន្ទប់នៃអាគារមួយខ្នង យុវនារីជាច្រើននាំគ្នាមកសិក្សារៀនសូត្រជំនាញផ្សេងៗ ដើម្បីយកទៅប្រកបការងារចិញ្ចឹមជីវិត។

អ្នកគ្រូសូត្រ ម៉ាឡែន ជាគ្រូផ្នែកសំអាងកាយកំពុងបង្រៀនយុវនារីអំពីរបៀបនៃការធ្វើសក់ ធ្វើក្រចក ដែលមានកូនសិស្សប្រមាណជិត១០នាក់ ដែលស្ថិតនៅក្នុងមណ្ឌលសិក្សាវិជ្ជាជីវៈរបស់អង្គការការីតាសកម្ពុជា ស្ថិតក្នុងឃុំស្នឹង ស្រុកបាណន់ ខេត្តបាត់ដំបង។

យុវតីយ៉េន ស្រីយ៉ា អាយុ២៤ឆ្នាំបានឲ្យដឹងថា "រៀនចប់ថ្នាក់ទី៨។ ចង់បានជំនាញមួយខ្លួនឯងពិតប្រាកដដើម្បីអាចចិញ្ចឹមខ្លួនឯងនិងម៉ែពុក"។ តាមការរៀបរាប់របស់ស្រីយ៉ា នាងរៀនបានត្រឹមថ្នាក់ទី៨តែប៉ុណ្ណោះ ដោយសារតែជីវភាពគ្រួសារខ្សត់ខ្សោយ ហើយនាងរៀនមិនសូវពូកែដូចគេ។

ខណៈពេលកំពុងរៀនក្នុងមណ្ឌលនេះ ស្រីយ៉ាមានសង្ឃឹមថា នាងនឹងអាចរកការងារធ្វើបាននឹងគេ ហើយក៏មានសមត្ថភាពក្នុងការបម្រើការងារនៅតាមហាងនានា។ ស្រីយ៉ា "សង្ឃឹមព្រោះអីលោកគ្រូមានកន្លែងឲ្យទៅធ្វើស្រេចៗអីចឹង។ ខ្ញុំអត់ទាន់ចង់បើក (ហាងផ្ទាល់ខ្លួន) ព្រោះអីចង់ទទួលបានបទពិសោធពីគេសិន"។ មិនសូវខុសគ្នាពីស្រីយ៉ាឡើយ យុវនារីប៊ូ សុផ័ត្ដណា អាយុ១៤ឆ្នាំមកពីឡែម ក្នុងខេត្តបន្ទាយមានជ័យឲ្យដឹងថាថា ដោយសារចំណូលចិត្តរបស់នាងតាំងពីវ័យកុមារមក និងដោយសារជីវភាពខ្វះខាតគ្មានឪពុកម្ដាយផ្គត់ផ្គង់ផងនោះ សុផ័ត្ដណាបានសម្រេចចិត្តមករៀនជំនាញសំអាងកាយនេះ ដើម្បីចិញ្ចឹមជីវិត។ សុផ័ត្ដណា "ម៉ាក់ប៉ាស្លាប់អស់ហើយ។ ខ្ញុំគុំតាំងពីតូច ថាខ្ញុំរៀនអាហ្នឹងឲ្យបាន។ ខ្ញុំចេះអស់ហើយតែនៅស្ទើរតិចៗ។ ស្ទើរគូសផ្កាក្រចកតែសម្រាប់មុខធ្វើបាន"។

អង្គការីតាស់កម្ពុជាបានបើកជំនាញនេះក្នុងឆ្នាំ២០១៥ ដែលមានគោលដៅចម្បង គឺផ្ដល់នូវជំនាញពិតប្រាកដមួយសម្រាប់ស្ត្រីកម្ពុជា ដើម្បីអាចផ្គត់ផ្គង់ជីវភាពក្នុងគ្រួសាររបស់ពួកគាត់។ នៅក្នុងមណ្ឌលសិក្សាវិជ្ជាជីវៈរបស់អង្គការការីតាសកម្ពុជានេះ មាន៥ជំនាញធំៗគឺ ជំនាញកាត់ដេរសម្លៀកបំពាក់ ជំនាញតម្បាញ ជំនាញសំអាងកាយ ជំនាញធ្វើម្ហូប និងជំនាញសណ្ឋាគារនិងបដិសណ្ឋារកិច្ច។

លោកយឿន វណ្ណា ជាមន្ត្រីគ្រប់គ្រងមណ្ឌលសិក្សានេះ មានប្រសាសន៍ថា កម្មវិធីទាំង៥នេះគឺផ្ដល់ជូនសម្រាប់ក្រុមគោលដៅស្ត្រីដែលងាយរងគ្រោះដូចជាអំពើហិង្សាក្នុងគ្រួសារ ការជួញដូរផ្លូវភេទ។ លោកបន្តថា គម្រោងនេះ ក៏ផ្ដល់ជូននូវកន្លែងស្នាក់នៅក្នុងអំឡុងពេលដែលយុវនារី និងស្ត្រីៗមកទទួលវគ្គសិក្សានៅក្នុងកម្មវិធីនេះ។ ជាមួយគ្នានេះដែរ ក្រៅពីជំនាញអង្គការការីតាសក៏មានបន្ថែមនូវ បំនិនជីវិតសម្រាប់ពួកគាត់ផងដែរ។ ក្នុងនោះរួមមានសួនដំណាំលក្ខណៈគ្រួសារ ការចិញ្ចឹមសត្វខ្នាតតូច និងវគ្គគ្រប់គ្រងអាជីវកម្មខ្លីៗ។

លោកវណ្ណា "បំនិនជីវិតហ្នឹង គឺរៀបចំដើម្បីឲ្យពួកគាត់ទទួលបានជំនាញបន្ថែមដើម្បីធានាថា នៅពេលគាត់ត្រឡប់ទៅសហគមន៍របស់គាត់វិញគាត់អាចធ្វើអ្វីខ្លះបានសម្រាប់គ្រួសាររបស់គាត់"។ ប្រធានគ្រប់គ្រងរូបនេះបន្តថា ក្រោយពីបញ្ចប់ការសិក្សានៅអង្គការការីតាស អង្គការក៏មានគម្រោងផ្ដល់នូវសម្ភារមួយចំនួនសម្រាប់អ្នកបើកអាជីវកម្មផ្ទាល់ខ្លួន។ លោកវណ្ណា "នៅពេលដែលគាត់ចប់វគ្គនឹងទៅគឺយើងនឹងទិញសម្ភារជូនគាត់អាស្រ័យលើជំនាញរបស់គាត់។ ឧ.ដូចជាកាត់ដេរ សំអាងកាយសិប្បកម្ម គឺឲ្យគាត់ជាម៉ាកញ្ចប់ដើម្បីឲ្យគាត់អាចត្រឡប់ទៅសហគមន៍បាន ប៉ុន្តែបើមានអ្នកណាចង់ចាប់ផ្ដើមជាអាជីវកម្ម ដូចជាគាត់បើកហាងយើងនឹងមានកញ្ចប់ថវិកាផ្សេង ហើយយើងសុំសិក្សាលំអិតជាមួយក្រុមគ្រួសារ ដូចជាគម្រោង ផែនការអាជីវកម្ម គម្រោងផែនការចំណាយ ដូច្នេះយើងត្រូវការពេលវែងដើម្បីសិក្សា"។

មណ្ឌលសិក្សាវិជ្ជាជីវៈរបស់អង្គការការីតាសកម្ពុជា មានសិស្សប្រមាណជាង១៦០នាក់បានបញ្ចប់ និងកំពុងត្រៀមបញ្ចប់ការសិក្សាក្នុងពេលបច្ចុប្បន្ននេះ។ អង្គការការីតាសកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលមួយរបស់ព្រះសហគមន៍កាតូលិក នៅកម្ពុជា ដែលធ្វើការងារផ្នែកមនុស្សធម៌ ដោយជួយដល់ប្រជាជនក្នុងមូលដ្ឋាន អំពីការអប់រំ អភិវឌ្ឍជនបទ សុខាភិបាល សុខភាពភ្នែក សុខភាពផ្លូវចិត្ត ជាមួយពលករចំណាក់ស្រុក បម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយជាដើម។

*ដោយ កញ្ញា*



ថតដោយ: កញ្ញា

# បេក្ខជន៦៧នាក់ទទួលអគ្គសញ្ញាលាបថ្វាសនៅព្រះវិហារសន្ត អង់ទន់ កោះទាវ



ថតដោយ: សុធីរិទ្ធ

បេក្ខជន បេក្ខនារី៦៧នាក់មកពីព្រះសហគមន៍ទាំង៦នៃមណ្ឌលសកម្មភាពបាសាក់ បានជួបគ្នានៅព្រះវិហារសន្តអង់ទន់ ក្នុងភូមិកោះទាវ ស្រុកកោះធំ ដើម្បីទទួលព្រះវិញ្ញាណដ៏វិសុទ្ធ (អគ្គសញ្ញាលាបថ្វាស) និងចូលរួមពិធីប្រទានព្រះពរលើជើងជួងថ្មី នាថ្ងៃទី៦ ឧសភា ២០១៨ ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ឆ្មីតអីស្លែរ ព្រមទាំងមានគ្រីស្តបរិស័ទជាច្រើនកុះករមកចូលរួមផងដែរ។

មុនចាប់ផ្ដើមថ្វាយអភិបូជា លោកអភិបាល លោកបូជាចារ្យ បេក្ខជន និងគ្រីស្តបរិស័ទទាំងអស់បានជុំគ្នាអធិដ្ឋាននៅមុខជួង និងជើងជួងថ្មីដើម្បីទូលសូមអង្វរព្រះជាម្ចាស់ប្រទានព្រះពរលើសំណង់ និងជួងថ្មីនេះដែលសម្លេងជួងជាសញ្ញាដាស់តឿនគ្រីស្តបរិស័ទឲ្យមកចូលរួមអធិដ្ឋាន។

នៅក្នុងធម្មទេសនា លោកអភិបាលមានប្រសាសន៍ថា "ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់" ហេតុនេះលោកណែនាំឲ្យគ្រីស្តបរិស័ទមានចិត្តស្រឡាញ់ មានអំណរសប្បាយ ព្រមទាំងអធិដ្ឋានជានិច្ចដើម្បីមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក ព្រោះព្រះជាម្ចាស់ចង់ឲ្យយើងមានជីវិត មានសុភមង្គល និងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ដែលរស់នៅក្នុងសេចក្ដីស្រឡាញ់។

បន្ទាប់ពីធម្មទេសនាលោកអភិបាលបានសួរបញ្ជាក់អំពីជំនឿរបស់បេក្ខជនចំពោះព្រះជាម្ចាស់នៅក្នុងពិធីទទួលអគ្គសញ្ញាលាបថ្វាស និងប្រកាសធម៌ជឿរួមជាមួយគ្រីស្តបរិស័ទទាំងអស់ រួចទូលអង្វរព្រះជាម្ចាស់រួមជាមួយសន្តបុគ្គលទាំងអស់ដើម្បីសូមព្រះវិញ្ញាណយាងមកគង់សណ្ឋិតជាមួយបេក្ខជនទាំងនោះ ដើម្បីឲ្យពួកគេទទួលបានផលផ្លែនៃព្រះវិញ្ញាណគឺ ព្រះវិញ្ញាណដែលនាំឲ្យមានប្រាជ្ញាឈ្លាសវៃ ដឹងខុសដឹងត្រូវ ដឹងអំពីសេចក្ដីពិត មានយោបល់ល្អ មានសេចក្ដីអង់អាច ប្រព្រឹត្តតាមការណែនាំរបស់ព្រះវិញ្ញាណ និងចេះគោរពកោតខ្លាចព្រះជាម្ចាស់ជាព្រះបិតា។

បេក្ខនារី យាង ធារី មកពីព្រះសហគមន៍ស្អាងបានឲ្យដឹងថា អគ្គសញ្ញានេះពិតជាមានប្រយោជន៍ខ្លាំងព្រោះបាននាំផលផ្លែដល់ទៅប្រាំពីរដែលអាចផ្ដល់កម្លាំង និងទទួលយកព្រះជាម្ចាស់បានច្រើនជាងមុន។នាងថា"គឺថាមពលពីព្រះវិញ្ញាណដ៏វិសុទ្ធជួយឲ្យខ្ញុំមានជំនឿលើព្រះយេស៊ូខ្លាំងជាងមុនទៀត"។ ធារីបន្តថា បន្ទាប់ពីបានទទួលអគ្គសញ្ញានេះហើយនឹងព្យាយាមធ្វើល្អតាមការណែនាំរបស់ព្រះជាម្ចាស់ ហើយប្រសិនបើមានអ្នកជិតខាងសួរ គឺនាងនឹងប្រាប់អំពីដំណឹងល្អរបស់ព្រះជាម្ចាស់តាមជំនឿរបស់ខ្លួនដល់ពួកគេទាំងអស់។

ព្រះសហគមន៍ទាំងប្រាំមួយដែលបេក្ខជន បេក្ខនារីមកនោះគឺ ព្រះសហគមន៍ជ្រៃធំ ព្រះសហគមន៍ស្អាង ព្រះសហគមន៍កោះទាវ ព្រះសហគមន៍ទួលក្រសាំង ព្រះសហគមន៍សំប៉ាន និងព្រះសហគមន៍បឹងឈូក។ ព្រះសហគមន៍ទាំងនោះស្ថិតក្រោមការណែនាំរបស់លោកបូជាចារ្យសិលា ឡេវ៉ាន់ទីន៕

*ដោយ ដាលីស*

# ៦៥ នាក់ទទួលជំហានទីមួយ ចូលក្នុងព្រះសហគមន៍កាតូលិក



ថតដោយ: សុធីរិទ្ធ

កាលពីថ្ងៃទី២៤ មិថុនា ២០១៨ ជាថ្ងៃបុណ្យរំលឹកកំណើតរបស់លោកយ៉ូហានបាទីស្ត ព្រះវិហារសន្តីម៉ារីញញឹម នៃព្រះសហគមន៍ចំការទៀង ក្នុងខេត្តតាកែវ បានទទួលបេក្ខជនសុំចូលព្រះសហគមន៍ចំនួន ៦៥នាក់ ដែលមកពីព្រះសហគមន៍សន្តប៉ូលចំការទៀង ត្រពាំងក្រញូង ភូមិសុខសាន្ត តាកែវក្រុង ដែលស្ថិតក្នុងមណ្ឌលកម្មភាពខេត្តតាកែវ។ កម្មវិធីនេះ បានប្រារព្ធក្រោមអធិបតីភាពរបស់លោកអូលីវីយេ ដ្មឹតអឺស្ទែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកបូជាចារ្យដែលបម្រើការងារនៅមណ្ឌលកម្មភាពតាកែវ និងតំណាងគ្រីស្តបរិស័ទមកពីព្រះសហគមន៍នានាក្នុងភូមិភាគនេះ។

មុនពេលចាប់ផ្តើមកម្មវិធីនេះ បេក្ខជនទាំងអស់បានឈរនៅមុខព្រះវិហារ ដែលមានគ្រីស្តបរិស័ទជាច្រើនកំពុងរៀបចំអភិបូជា ហើយពួកគាត់បានគោះទ្វារព្រះវិហារដោយមានសំណួរពីលោកអភិបាល។

ក្រោយពីការឆ្លើយសំណួរ ព្រះសហ-គមន៍បានបើទ្វារទទួលបងប្អូលចូលក្នុងព្រះវិហារ និងគ្រីស្តបរិស័ទទាំងអស់ទទួលស្វាគមន៍បងប្អូនបេក្ខជនទាំង៦៥នាក់។ ពិធីអភិបូជាក៏ចាប់ផ្តើម។

បន្ទាប់មកបេក្ខជនម្នាក់ម្តងបង្ហាញខ្លួនចំពោះមុខ លោកអភិបាល និងព្រះសហ-គមន៍។ លោកអភិបាល បានគូសសញ្ញាឈើឆ្កាងលើបាតដៃរបស់បេក្ខជន និងបេក្ខនារីទាំងអស់ ដោយប្រេងសម្រាប់លាបលើអ្នកទទួលអប់រំជំនឿ។ បន្ទាប់មកលោកអភិបាលបានឲ្យបងធម៌ទាំងអស់មកគូសសញ្ញាឈើឆ្កាងលើបេក្ខជន ដែលជាប្អូនធម៌របស់ខ្លួន គឺមានភ្នែក ត្រចៀក មាត់ ដៃ និងទ្រូង។

ក្រោយពីបានស្តាប់ព្រះបន្ទូលរួចមក និងបានប្រកាសជំនឿចំពោះមុខព្រះសហ-គមន៍ បេក្ខជន និងបេក្ខនារីទាំងអស់បានឡើងម្តងមួយក្រុម អុជធូប នៅមុខព្រះ គម្ពីរ ឈើឆ្កាង និងព្រះសហគមន៍ដោយប្រកាសយ៉ាងខ្លាំងៗថា "ខ្ញុំសូមយកព្រះគ្រីស្តជាទីពឹង ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង"។

នៅក្នុងធម្មទេសនា លោកអភិបាលអូលីវីយេមានប្រសាសន៍រំលឹកពីលោកយ៉ូ-ហានបាទីស្ត ដែលជាបងជីដូនមួយរបស់ព្រះយេស៊ូ។ លោកមានប្រសាសន៍ថា ឈ្មោះយ៉ូហាននេះបកប្រែជាខ្មែរថា ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណា។ លោកយ៉ូហានជាជាព្យាការីចុងក្រោយ ដែលថ្លែងអំពីដំណឹងល្អ គឺព្រះសង្គ្រោះ។ តួនាទីរបស់គាត់គឺ ចង្អុលបង្ហាញព្រះគ្រីស្ត។ លោកអភិបាលក៏បានបញ្ជាក់ទៀតថា ក្នុងនាមជាគ្រីស្តបរិស័ទ យើងក៏មានតួនាទីដូចលោកយ៉ូហានដែរ គឺប្រកាសដំណឹងល្អ និងបង្ហាញព្រះយេស៊ូដល់បងប្អូនឯទៀតឲ្យបានស្គាល់ព្រះអង្គ និងឲ្យគេកែប្រែចិត្តគំនិត។

ជាមួយគ្នានេះដែរលោកអភិបាលបានចូលរួមអបអរមណ្ឌលសកម្មភាពតាកែវ ដែលថ្ងៃនេះ មានជំហានទីមួយ។ លោកមានប្រសាសន៍ថា ក្នុងឱកាសនោះដែរ លោកអភិបាលក៏បានរំលឹកដល់គ្រីស្តបរិស័ទឲ្យនៅជាប់ជាមួយព្រះជាម្ចាស់រហូត និងធ្វើជាគំរូសម្រាប់អ្នកឈ្វេងយល់ជំនឿទាំងឡាយ ដោយកុំឲ្យខកខានការមកជួបជុំថ្ងៃអាទិត្យ។

បេក្ខជន បេក្ខនារីទទួលជំហានទី១ចូលក្នុងព្រះសហគមន៍នៅមានថ្ងៃនេះមានវ័យខុសៗគ្នា មកពីប្រភពខុសៗគ្នា ខ្លះជាយុវសិស្ស មានស្ត្រីៗជាមេផ្ទះ មានស្ត្រីមេម៉ាយ មានជនពិការកាយសម្បទា មនុស្សគរ ថ្លង់ មានអ្នកផ្ទុកមេរោគអេដស៍ មានបុរសជាមេគ្រួសារជាដើម។ ពួកគេមានបានទទួលដំណឹងល្អតាមរយៈការងារនៃមេត្តាករុណាដែលព្រះសហគមន៍បានបំពេញជាពិសេស លោកអភិបាលអូលីវីយេផ្ទាល់បានយកចិត្តទុកចំពោះបងប្អូនទាំងនោះ។

ព្រះសហគមន៍កាតូលិក នៅតំបន់តាកែវ ជាព្រះសហគមន៍ដែលមានជីវិតយ៉ាងរស់រវីកនិងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបងប្អូនពុទ្ធបរិស័ទនៅក្នុងតំបន់ដែលបងប្អូនរស់នៅ។ បងប្អូនបានស្គាល់ព្រះសហគមន៍ និងនាមរបស់ព្រះយេស៊ូដោយសារសកម្មភាពមេត្តាករុណា និងការអភិវឌ្ឍ ក្នុងវិស័យអប់រំសិក្សា សម្រាប់បម្រើដល់បងប្អូនក្នុងតំបន់ជាអ្នកក្រីក្រ ជនពិការ ចាស់ជរា ជាដើម៕

# កុមារនូវសេឡង់២នាក់ស្លាប់ ក្រោយទទួល ថ្នាំបង្ការ

មានកុមារអាយុ១ខួបចំនួនពីរនាក់បានស្លាប់កាលពីថ្ងៃទី៦ កក្កដា នៅប្រទេសនូវសេឡង់ បន្ទាប់ពីពួកគេបានទទួលវ៉ាក់សាំងMMR ជាវ៉ាក់សាំងសម្រាប់បង្ការជំងឺស្អូច កញ្ជ្រិល និងស្រឡទែន។ នេះបើយោងតាមសារព័ត៌មានរបស់ប្រទេសនេះ។

សារព័ត៌មាននេះរាយការណ៍ថា ក្នុងថ្ងៃជាមួយគ្នានោះ មានកុមារីម្នាក់អាយុមួយឆ្នាំបានស្លាប់បន្ទាប់ពីទទួលវ៉ាក់សាំងនេះក្នុងរយៈពេល៣នាទីក្រោយមក។ ហើយ២ម៉ោងបន្ទាប់មានកុមារាម្នាក់ទៀតបានទទួលវ៉ាក់សាំងនេះដែរ ហើយបានស្លាប់មួយនាទីក្រោយមក នៅក្នុងមន្ទីរពេទ្យ សាហ្វុតុ (Safo tu) ក្នុងតំបន់ សាវៃអី (Savaii) នៃដែនកោះសាម៉ូន (Samoan)។

គ្រួសារកុមាររងគ្រោះបានរាយការណ៍ប្រាប់ប៉ូលីសក្នុងតំបន់ ហើយបានស្នើសុំឲ្យមានការស៊ើបអង្កេតជាបន្ទាន់មួយលើការស្លាប់របស់កូនៗរបស់ពួកគេ។

បច្ចុប្បន្នវ៉ាក់សាំងបង្ការជំងឺបីមុខនេះកំពុងត្រូវបានគេពិនិត្យនិងតាមដានអំពីប្រតិកម្មរបស់វាឡើងវិញ។

ក្នុងប្រទេសនូវសេឡង់ វ៉ាក់សាំងបង្ការជំងឺស្អូច កញ្ជ្រិល និងស្រឡទែននេះ ត្រូវបានណែនាំឲ្យប្រើប្រាស់សម្រាប់កុមារដែលមានអាយុពីសូន្យទៅដល់មួយខួប។ ទោះបីជាយ៉ាងណាក្រសួង សុខាភិបាលនៃប្រទេសនេះធ្លាប់បានឲ្យដឹងថា MMR ជាវ៉ាក់សាំងមានការទទួលស្គាល់ថាមានសុវត្ថិភាពខ្ពស់។

ក្រោយពី មានហេតុការណ៍នេះ ក្រសួងសុខាភិបាលនៃតំបន់សាម៉ូន បានបញ្ឈប់កុមារទាំងឡាយមិនឲ្យទទួលថ្នាំបង្ការនេះទៀតឡើយ៕

# យុវនារី តេរេសា ហេង ផល្លាថ្វាយពាក្យសច្ចាលើកដំបូងក្នុងជីវិតជាបព្វជិតា

កាលពីថ្ងៃទី២៣ មិថុនា ២០១៨នេះ ក្រុមគ្រួសារអ្នកបួស គឺបងស្រីអ្នកបម្រើនៃសេចក្តីស្រឡាញ់ដ៏និមលរបស់ព្រះនាងម៉ារីបានទទួលយុវជនារីតេរេសា ហេងផល្លា ជាសមាជិកថ្មី ដែលបានថ្វាយពាក្យសច្ចាប្រណិធានលើកដំបូង ក្រោមអធិបតីភាពរបស់លោកអេនរីគេ ហ្វីការេដូ ជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងលោកអន់តូនីសាមី ស៊ូសៃរាជ្យ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់-ចាម រួមនឹងលោកបូជាចារ្យនិងគ្រីស្តបរិស័ទជាច្រើនកុះករ ដែលធ្វើឡើងនៅព្រះវិហារសន្តយ៉ូហាន នៃព្រះសហគមន៍សៀមរាប ខេត្តសៀមរាប។

លោកអភិបាលអេនរីគេ ហ្វីការេដូ មានប្រសាសន៍បីចំណុចសំខាន់ៗសម្រាប់បងស្រីផល្លា គឺត្រូវស្រឡាញ់ព្រះយេស៊ូ ត្រូវស្រឡាញ់អ្នកក្រីក្រដោយបម្រើអ្នកក្រីក្រ និងត្រូវស្រឡាញ់ក្រុមគ្រួសារអ្នកបួស។

លោកអភិបាលបានមានប្រសាសន៍ថា បងស្រីត្រូវមានភក្តីភាព ចំពោះសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ដោយសារព្រះអង្គសុខចិត្តលះបង់ជីវិតសម្រាប់យើង។ កុំយកអ្វីផ្សេង ក្រៅពីភក្តីភាពចំពោះសេចក្តីស្រឡាញ់ គឺព្រះជាម្ចាស់។

លោកអភិបាលបន្តថា បងស្រីត្រូវយកពេលវេលាបម្រើអ្នកក្រីក្រ បម្រើដោយស្រឡាញ់អ្នកក្រីក្រ គឺជាមនុស្សដែលព្រះអង្គស្រឡាញ់។ ព្រះយេស៊ូមានចិត្តមេត្តាករុណា និងសេចក្តីស្រឡាញ់ចំពោះអ្នកក្រីក្រ។

ចំណុចចុងក្រោយលោកអភិបាលមានប្រសាសន៍ថា ត្រូវមានសេចក្តីស្រឡាញ់ក្នុងក្រុមគ្រួសារដែលកូនចូលរួម និងសាមគ្គីគ្នាដោយចិត្តស្រឡាញ់ គោរព និងដើរតាមដែលទង្វើនេះនាំអោយយើងដើរទៅមុខបានរហូត។

ដើម្បីអោយការទាំងនេះអាចមានដំណើរទៅបាន គឺត្រូវមានការអធិដ្ឋានជាប់ជានិច្ច។

បងស្រីហេង ផល្លាមានកំណើតនៅភូមិកោះរាម ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង។ គាត់ជាកូនច្បងនៃគ្រួសារដែលមានឪពុកម្តាយជាពុទ្ធបរិស័ទ និងជាកសិករ។

ផល្លាបានទទួលអគ្គសញ្ញាជ្រមុជទឹកជាគ្រីស្តបរិស័ទកាតូលិកនៅឆ្នាំ២០០៦ នៅព្រះវិហារព្រះយេស៊ូសម្តែងធម៌មេត្តា នៅព្រះសហគមន៍ខ្នាចរមាស ដែលមានលោក សិលា ទម្លាប់សុផល ជាបូជាចារ្យទទួលខុសត្រូវ។

ក្នុងឱកាសដ៏វិសេសវាសាលនេះលោកបូជាចារ្យ សិលា ទម្លាប់សុផល បានបង្ហាញសក្ខីភាពខ្លះអំពីបងស្រីផល្លា ដែលបានខិតខំស្វែងរកក្រុម និងឈ្វេងយល់អំពីជីវិតអ្នកបួស។ ចុងក្រោយសម្រេចចិត្តចូលក្នុងក្រុមគ្រួសារ បងស្រីបម្រើសេចក្តីស្រឡាញ់ដ៏និមលរបស់ព្រះនាងម៉ារី។ លោកបូជាចារ្យក៏បាន លើកនូវព្រះបន្ទូលមួយចំនួនដើម្បីបញ្ជាក់អត្ថន័យដែលបានចាក់ចេញពីគ្រួសារលោកីយ៍ទៅកាន់គ្រួសារមួយជាសាវ័ករបស់ព្រះយេស៊ូ។

ក្នុងវ័យ៣២ឆ្នាំបព្វជិតាថ្មីនេះ បានបន្លឺសម្លេងនៅមុខគ្រីស្តបរិស័ទទាំងឡាយ ដោយប្រកាសស្ម័គ្រចិត្តបម្រើព្រះជាម្ចាស់ ដោយដើរតាមមាគ៌ារបស់ក្រុមគ្រួសារអ្នកបម្រើនៃសេចក្តីស្រឡាញ់ដ៏និមលរបស់ព្រះនាងម៉ារី គឺរស់នៅដោយចិត្ត សុភាពរាប សារស្តាប់បង្គាប់ និងកាន់ព្រហ្មចារីធម៌។

ក្នុងកម្មវិធីនោះ បងស្រីបាន សម្តែងនូវសេចក្តីរីករាយ និងអរព្រះគុណព្រះជាម្ចាស់ចំពោះអំណោយទានគ្រប់បែបយ៉ាងដែលគាត់បានទទួលក្នុងជីវិត ទាំងឪពុកម្តាយដែលបានចិញ្ចឹមអប់រំនិងថែរក្សា លោកបូជាចារ្យនិងអស់បងប្អូនទាំងអស់។

បងស្រី និយាយថា "ខ្ញុំមានថ្ងៃនេះ ដោយសារពុកម៉ែ ដែលបានអប់រំផ្សះផ្សា និងអនុញ្ញាតឲ្យកូនបានបួស។ សូមព្រះជាម្ចាស់ជួយថែរក្សាពុកម៉ែ។ អរគុណបងស្រីទាំងអស់ដែលបានអប់រំ លើកទឹកចិត្តឲ្យខ្ញុំអាចដើរតាមព្រះយេស៊ូ"។

បងស្រី កែវគីង ផនធីប ជាប្រធានក្រុមគ្រួសារអ្នកបម្រើនៃសេចក្តីស្រឡាញ់ដ៏និមលរបស់ព្រះនាងម៉ារី នៅប្រទេសកម្ពុជាបានមានប្រសាសន៍ថា "ដូច្នេះ ដោយសារគាត់ទើបតែជាបងស្រីថ្មីៗ យើងចង់ថែរក្សាគាត់ ឲ្យគាត់ទៅថៃសិន។ បានបំពេញបេសកកម្មនៅប្រទេសថៃមួយឆ្នាំដើម្បីចូលរួមក្នុងក្រុមគ្រួសារបងស្រីថៃក្រោយមកទើបគាត់មកស្រុកខ្មែរវិញ"។

បងស្រីប្រធានបន្តថា យើងនឹងបន្តគាំទ្របងស្រីផល្លាដោយការអធិដ្ឋាន ហើយពេលដែលគាត់ត្រឡប់មកវិញ យើងសូមទទួលគាត់ជាសមាជិកនិងជាបងប្អូនក្នុងក្រុមគ្រួសារយើង។

ក្រុមគ្រួសារអ្នកបម្រើនៃសេចក្តីស្រឡាញ់ដ៏និមលរបស់ព្រះនាងម៉ារីបង្កើតឡើងនៅប្រទេសថៃក្នុងឆ្នាំ១៩៣៧ ដោយលោកអភិបាលផាសុទ្ធី (Pasotti) នៃក្រុមគ្រួសារសាលេស៊ាន។

បងស្រី ផនធីបបន្តថា "បេសកកម្មរបស់ក្រុមយើង ជាពិសេសគឺបម្រើព្រះ-សហគមន៍ដូចជា ការអប់រំជំនឿ ការចុះសួរសុខទុក្ខ និងបម្រើក្នុងវិស័យការសិក្សាអប់រំ។ យើងធ្វើការនៅទីនេះ (កម្ពុជា) ក្រោមការគ្រប់គ្រងរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង"។

បងស្រី ក៏សូមឲ្យគ្រីស្តបរិស័ទជួយទូលអង្វរព្រះជាម្ចាស់សូមឲ្យមានយុវនារីអាចថ្វាយខ្លួនដើម្បីបម្រើព្រះសហគមន៍ឲ្យ បានច្រើន ជាពិសេសក្នុងប្រទេសកម្ពុជា។

ក្រុមគ្រួសារបងស្រីបម្រើសេចក្តីស្រ-ឡាញ់ដ៏និមលរបស់ព្រះនាងម៉ារី បានមកដល់ប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៦ កំពុងបម្រើការងារព្រះសហគមន៍កាតូលិកនៅខេត្តកំពង់ធំ និងខេត្តសៀមរាប៕



ថតដោយ : អានរិទ្ធីរ័ត្ន

# លោកយាយសារីយ៉េ និងលោកយាយប៉េឡាជី ចាកចេញពីកម្ពុជាហើយ

ដូនជីកាតូលិក នៃក្រុមគ្រួសារអ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ លោក យាយ សារីយ៉េ និងលោកយាយ ប៉េឡាជី នាថ្ងៃទី១២ ខែមិថុនានេះបានចាកចេញពីប្រទេសកម្ពុជា ហើយតាមច្រកព្រំដែនអន្តរជាតិ ដាំស្រងាំ ដោយមានការជូនដំណើរដោយផ្ទាល់ ដោយលោកអភិបាលអន់តូនី អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ព្រមទាំងលោកបូជាចារ្យ និងក្រុមដូនជីកាតូលិកនៃក្រុមអ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូទាំងអស់។

លោកយាយទាំងពី បានមកបំពេញបេសកកម្មនៅកម្ពុជាចំនួន២៥ឆ្នាំ ហើយជាពិសេសនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។ ការចាកចេញនេះគឺពិតណាស់ពិបាកទទួលយកព្រោះមានអនុស្សាវរីយ៍ជាច្រើន មានមនោសញ្ចេតនាជ្រាលជ្រៅបំផុត ជាប់ជាមួយកូនៗ ចៅៗ ជាគ្រីស្តបរិស័ទ ដែលលោកយាយបានជួនថែរទាំ និងណែនាំអប់រំ។ មានសារជាច្រើនបានផ្ញើជូនគ្នាទៅវិញទៅមកក្នុងចំណោមគ្រីស្តបរិស័ទ ដែលបានស្គាល់លោកយាយរៀបរាប់ពីគុណសម្បត្តិ និងស្នារដៃរបស់លោកយាយដែលមានចំពោះពួកគេម្នាក់ៗ។ ក្នុងនោះក៏មានពាក្យជូនពរ និងពាក្យអង្វរព្រះជាម្ចាស់ប្រទានពរសម្រាប់បេសកកម្មថ្មី និងប្រទានសុខភាពល្អ តាមថែរក្សាលោកយាយក្នុងការរស់នៅ។

លោកយាយ សារីយ៉េ និងលោកយាយ ប៉េឡាជី បានចូលមកប្រទេសកម្ពុជាតាមរយៈ ក្រុមសាសនទូតថៃ TMS (Thai missionaries society) ដើម្បីបម្រើដំណឹងល្អ ក្នុងភូមិភាគកំពង់ចាម គឺចាប់តាំងពីព្រះសហគមន៍នៅកម្ពុជាបានរស់ឡើងវិញក្រោយសង្គ្រាមស៊ីវិល។ ក្នុងរយៈឆ្នាំ២៥នេះ លោកយាយទាំងពីរបានខិតខំអស់កម្លាំងកាយចិត្តបម្រើព្រះសហគមន៍ក្នុងភូមិភាគកំពង់ចាម ដោយបម្រើក្នុងពិធីបុណ្យ បម្រើបងប្អូនក្រីក្រ និងអប់រំជំនឿដល់បងប្អូន ដោយសុភាពរាបសា ទាំងចិត្តកាយ និងវាចា ប្រកបដោយជំនឿរឹងមាំជាគំរូដល់អស់បងប្អូន។

ដោយសារព្រះអំណោយទាន និងគំរូទាំងនេះហើយ បង្កលក្ខណៈពិសេសឲ្យបងស្រីអាចបង្កើតក្រុមអ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូនៅកំពង់ចាម ក្រោមការជ្រោមជ្រែងរបស់លោកអភិបាលព្រះសហគមន៍។ លោកយាយទាំងពីរជាគ្រាប់ពូជពិសេស ដែលធ្វើឲ្យក្រុមដូនជីកាតូលិកមួយនេះដុះឡើងវិញនៅកម្ពុជា ក្រោយពីក្រុមនេះបានចាកចេញពីប្រទេសកម្ពុជាដោយសារសង្គ្រាមនៅទសវត្សទី៧០។ រហូតមកដល់ពេលនេះ មានយុវនារីកម្ពុជា៤នាក់បានថ្វាយពាក្យសច្ចានិរន្តរ៍ ២នាក់ថ្វាយពាក្យសច្ចាលើកទី១ និង២នាក់ទៀតស្ថិតនៅជាសាមណេរី (ប៉ុស្តូឡាំង)៕ *ដោយ សុវណ្ណា*



ថតដោយ : មីញ

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រា ៤៤**

ករណីដែលពាក់ព័ន្ធនឹងបណ្ណពិន្ទុ ៖

- ក្នុងករណីអស់ពិន្ទុបណ្ណបើកបរត្រូវទុកជាមោឃៈ។ អ្នកបើកបរមានបំណងចង់បានបណ្ណបើកបរថ្មី ត្រូវរៀន និងប្រឡងយកបណ្ណបើកបរឡើងវិញក្នុងរយៈពេលយ៉ាងតិច ៦(ប្រាំមួយ)ខែ ចាប់ពីថ្ងៃដែលបណ្ណបើកបរត្រូវទុកជាមោឃៈ លើកលែងតែអ្នកបើកបរបង្កឲ្យមានរបួសដល់អ្នកដទៃដោយអចេតនា ហើយបណ្តាលឲ្យអ្នករងគ្រោះមានអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើ ឬលើសពី ៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុឬស្លាប់អ្នកបើកបរអាចរៀននិងប្រឡងយកបណ្ណបបើកបរជាថ្មីឡើងវិញក្នុងរយៈពេលយ៉ាងតិច ៥(ប្រាំ)ឆ្នាំ ចាប់ពីថ្ងៃដែលបណ្ណបើកបរត្រូវទុកជាមោឃៈ
- ក្នុងករណីដែលពិន្ទុត្រូវបានកាត់បន្ថយមួយចំនួនហើយ ប៉ុន្តែក្នុងរយៈពេល ៣(បី) ឆ្នាំ បន្ទាប់ពីការដកពិន្ទុចុងក្រោយអ្នកបើកបរមិនបានធ្វើឲ្យមានកំហុសអ្វីមួយថែមទៀតដើម្បីឲ្យកាត់បន្ថយពិន្ទុនោះអ្នកបើកបរត្រូវទទួលបណ្ណពិន្ទុថ្មីដែលមាន១២(ដបពីរ)ពិន្ទុដោយស្វ័យប្រវត្តិ។
- ក្នុងករណីដែលពិន្ទុត្រូវបានកាត់បន្ថយមួយចំនួនហើយប៉ុន្តែអ្នកបើកបរចង់បង្កើនពិន្ទុឡើងវិញត្រូវធ្វើការរៀនបំប៉នរយៈពេល ២ (ពីរ) ថ្ងៃ ដែលរៀបចំឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ ក្នុងការរៀននេះពិន្ទុអាចកើនឡើង ៤ (បួន) ពិន្ទុ ប៉ុន្តែមិនអនុញ្ញាតឲ្យមានចំនួនសរុបលើសពី ១១(ដប់មួយ) ពិន្ទុឡើយ។ អ្នកបើកបរអាចរៀនបានច្រើនដង ដើម្បីបង្កើនក្នុងរយៈពេល ២ (ពីរ) ឆ្នាំយ៉ាងយូរ ។

នីតិវិធីនៃការដកនិងបំពេញពិន្ទុឡើងវិញសម្រាប់បណ្ណបើកបរត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៤៥**

លើកលែងតែមានកិច្ចព្រមព្រៀង ឬអនុញ្ញាតអន្តរជាតិទទួលស្គាល់បណ្ណបើកបរទៅវិញទៅមកជាទ្វេភាគី ឬពហុភាគីជាមួយព្រះរាជាណាចក្រកម្ពុជាជនបរទេសដែលចូលមកស្នាក់នៅស្របច្បាប់ហើយមានបំណងបើកបរ លើផ្លូវថ្នល់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានបណ្ណបើកបរកម្ពុជាតាមមធ្យោបាយពីរយ៉ាង ៖

១.ត្រូវប្រឡងយកបណ្ណបើកបរដូចប្រជាពលរដ្ឋខ្មែរដែរ។

២.ត្រូវយកបណ្ណបើកបររបស់ប្រទេសខ្លួនមកប្តូរយកបណ្ណបើកបរកម្ពុជាដោយដាក់ពាក្យសុំនៅក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

ក.ត្រូវមានលិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព។

ខ.ត្រូវមានបណ្ណបើកបរមានសុពលភាព។

គ.មានអាសយដ្ឋានច្បាស់លាស់ដោយមានសេចក្តីបញ្ជាក់របស់មេឃុំ ឬចៅសង្កាត់។

ឃ. មានលិខិតបញ្ជាក់កាយសម្បទា។

ង.ក្នុងករណីដែលបណ្ណបើកបរមិនសរសេរជាអក្សរជាភាសាអង់គ្លេសឬភាសាបារាំង ត្រូវតែបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស ឬភាសាបារាំងដោយមានការបញ្ជាក់ទទួលស្គាល់ពីស្ថានទូត ឬទីស្ថានកុងស៊ុល ឬទីស្ថានរបស់បេសកកម្មរបស់ខ្លួន។

សុពលភាពបណ្ណបើកបររបស់ជនបរទេសដែលត្រូវបានប្តូរយកបណ្ណបើកបរកម្ពុជារយៈពេល១(មួយ)ឆ្នាំ។ សុពលភាពបណ្ណបើកបររបស់ជនបរទេសដែលបានប្រឡងជាប់មានរយៈពេលដូចគ្នានឹងពលរដ្ឋខ្មែរដែរ។

ជនបរទេសដែលមានបណ្ណបើកបរប្រភេទ គ ឃ និង ង មិនអាចប្តូរយកបណ្ណបើកបរប្រភេត ក និង ខ បាន៕

(មានតនៅលេខក្រោយ)

# ព្រះសហគមន៍ភូមិភាគបាត់ដំបង មានអាគារអប់រំជំនឿថ្មី



ថតដោយ : លី សុវណ្ណា

កាលពីថ្ងៃទី២៩ ខែមិថុនា ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានបើកសម្ពោធអគារប្រកាសដំណឹងល្អសន្ត ក័រឡូស បូរ៉ូមេ ក្រោមអធិបតីភាពរបស់លោកអេនរីគេហ្វីការេដ្ឋូអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងលោក អន់តូនីសាមី ស៊ូសៃរាជ្យ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមរួមនិងលោកបូជាចារ្យ និងគ្រីស្តបរិស័ទជាច្រើនកុះករ ដែលប្រារព្ធនៅក្នុងបរិវេណព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្នុងខេត្តបាត់ដំបង។

អគារដែលមានបន្ទប់ធំទូលាយជាច្រើនដើម្បីបម្រើការងារក្នុងវិស័យប្រកាសដំណឹងល្អនេះមាន កម្មវិធីអប់រំជំនឿ ពង្រឹងសមត្ថភាពគ្រូអប់រំជំនឿពង្រឹងនិងសិក្សាអំពីជំនឿសម្រាប់គ្រីស្តបរិស័ទកាតូលិកក្នុងភូមិភាគបាត់ដំបង និងជាកន្លែងធ្វើសកម្មភាពសម្រាប់គណៈកម្មការគម្ពីរអន្តរភូមិភាគ។

កម្មវិធីនេះ ចាប់ផ្តើមឡើង ដោយមានពិធីដង្ហែក្បួនមុខវិហារតូច ឆ្ពោះទៅកាន់អគារថ្មីពណ៌ស ដោយមានកាត់ខ្សែបូ និងបើករូបសំណាកសន្តសិលា និងសន្តប៉ូ។ បន្ទាប់មកជាងសំណង់ បានប្រគល់សោរអគារជូនលោកអភិបាលអេនរីគេ ហើយលោកបានប្រគល់បន្តជូនលោកបូជាចារ្យតម្លាប់ សុផល ដើម្បីចាត់ចែងប្រើប្រាស់តាមសេចក្តីត្រូវការរបស់ព្រះសហគមន៍ក្នុងភូមិភាគនេះ។

ក្នុងអភិបូជា លោកអភិបាលអន់តូនីមានប្រសាសន៍ថា ទោះនៅក្នុងកិច្ចការលំបាកយ៉ាងណា មានតែការទុកចិត្តលើព្រះជាម្ចាស់ និងការអធិដ្ឋាននៅជិតស្និទ្ធជាមួយព្រះអង្គប៉ុណ្ណោះ ទើបជីវិតអាចរីចម្រើនឡើង។

លោកអភិបាលមានបញ្ជាក់ថា តាមរបៀបរបស់លោកសិលាក្នុងអត្ថបទថ្ងៃនេះ ទោះជាគាត់ជាប់ឃុំ ក៏គាត់អាចសម្រាកស្រួលដោយសារលោកដឹងថាព្រះសហគមន៍នៅអធិស្ឋានសម្រាប់គាត់។ លោកសិលាមានសង្ឃឹម ដោយសារព្រះយេស៊ូមានព្រះជន្មថ្មី។ មានន័យថា ព្រះជាម្ចាស់ចាំរំដោះយើងគ្រប់ពេល ហើយរំលឹកយើងដែលជាព្រះសហគមន៍ត្រូវតែអធិស្ឋាន ទោះបីមានការងាររវល់យ៉ាងណា ត្រូវមានពេលបន្តិចអធិស្ឋាន។

លោកអភិបាលបានរំលឹកទៀតថា ទោះជាយ៉ាងណា ក្នុងការរស់នៅជាគ្រីស្តបរិស័ទ យើងត្រូវបន្តអប់រំខ្លួនឯង ដោយរៀនពីគម្ពីរ និងទេវវិទ្យា និងអនុវត្តន៍តាម ហើយគ្រីស្តបរិស័ទ ដែលទាក់ទងនឹងអ្នកដទៃត្រូវចេះឆ្លើយសំណួរគេ គឺត្រូវត្រៀមខ្លួន និងចេះអប់រំខ្លួនរហូត។

លោកបូជាចារ្យទម្លាប់ សុផល ទទួលបន្ទុកកិច្ចការប្រកាសដំណឹងល្អនៅក្នុងភូមិភាគបាត់ដំបង មានប្រសាសន៍អំពីការអធិដ្ឋាន គឺសូមឲ្យគ្រីស្តបរិស័ទ មុនគេបង្អស់នៃការអធិដ្ឋាន គឺត្រូវសុំសម្រាប់ព្រះសហគមន៍ដោយឥតសាកស្រាន្ត ត្រូវអរគុណព្រះជាម្ចាស់ឥតសាកស្រាន្ត ដោយគិតពីព្រះសហគមន៍ព្រះជាម្ចាស់មុនគ្រួសារផ្ទាល់ខ្លួន។

លោកបូជាចារ្យ រំលឹកដល់គ្រីស្តបរិស័ទទាំងអស់ត្រូវស្វែងរកអ្នក ដែលមិនមកព្រះវិហារ។ "ពេលណាយើងទៅរកកូនចៀម ត្រូវនិយាយដោយសុភាព កុំស្តីឲ្យគេដើម្បីឲ្យគេវិលមកវិញ"។ លោកបន្តថានេះជាកង្វល់របស់លោកអភិបាលគ្រប់ព្រះសហគមន៍នាពេលសព្វថ្ងៃនេះ។

រឿត ៉រ៉ុធ សមាជិកគណៈកម្មាការអប់រំជំនឿ ឲ្យដឹងថា"មណ្ឌលនេះគឺសំខាន់មែនទែនសម្រាប់ភូមិភាគ ជាពិសេស អប់រំជំនឿក្នុងការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រចាំ និងអំពីគរុកោសល្យ។ ជាពិសេសជួយឲ្យខ្ញុំ អាចមានឱកាសចែករំលែកបទពិសោធន៍ និងព្រះបន្ទូលដែលខ្ញុំទទួលបាន។ ជួយលើកទឹកចិត្តគ្នាទៅវិញទៅមកពេលយើងមករៀន និងពេលយើងមានបញ្ហានៅពេលអប់រំ ការរស់នៅជាគ្រីស្តបរិស័ទ... ជួយយើងអាចធ្វើដំណើរទៅមុខបាន"។

លោកអភិបាល អេនរីគេ មានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានយើងថា អគារនេះនឹងប្រើការសម្រាប់ព្រះសហគមន៍ទូទាំងប្រទេស ជាពិសេសគឺយើងចង់ប្រកាសថាគ្រូអប់រំជំនឿមានសារៈសំខាន់សម្រាប់ព្រះសហគមន៍។ លោកអភិបាល បន្តថា ដើម្បីឲ្យព្រះសហគមន៍ទៅខាងមុខ យើងត្រូវមានគ្រឹះ មានគ្រូអប់រំដ៏ល្អ ដែលយកចិត្តទុកដាក់អប់រំជំនឿ ដូច្នេះយើងត្រូវមាន កន្លែងល្អ មានបរិយាកាសទទួលស្វាគមន៍។ លោកអភិបាល សូមអរព្រះគុណព្រះជាម្ចាស់ចំពោះគ្រូអប់រំជំនឿ ដែលមានចិត្តល្អ យកចិត្តទុកដាក់ចំពោះព្រះសហគមន៍។ លោកអភិបាល "ខ្ញុំគិតថានៅក្នុងស្រុកខ្មែរយើងមានគ្រូអប់រំល្អច្រើនណាស់ មានចិត្តមានចំណេះដឹង និងមានតួនាទីពិសេសក្នុងព្រះសហគមន៍។ ប្រសិនបើយើងអត់យកចិត្តទុកដាក់អំពីគាត់ យើងទៅមុខអត់បាន។ លោកគ្រូអ្នកគ្រូ ត្រូវដឹងច្បាស់ គាត់មានសារៈសំខាន់សម្រាប់ព្រះសហគមន៍។ ដូច្នេះក្នុងនាមខ្ញុំជាបុគ្គលម្នាក់ត្រូវណែនាំព្រះសហគមន៍ ខ្ញុំពឹងនឹងពួកគាត់ ដើម្បីយើងទៅខាងមុខ"។

បច្ចុប្បន្នអាគារប្រកាសដំណឹងល្អសន្តក័រឡូស បូរ៉ូមេ នេះកសាងឡើងក្រោមការឧបត្ថម្ភរបស់អង្គការបេសកកម្ម ហើយអគារនេះដែរប្រើប្រាស់សម្រាប់សកម្មភាពពីរសំខាន់ៗគឺបណ្តុះបណ្តាលអ្នកអប់រំជំនឿរបស់ភូមិភាគរៀងរាល់ខែ នៅចុងសប្តាហ៍ទី៣។ ជាពិសេស គឺបណ្តុះបណ្តាលគុណភាព និងសមត្ថភាពអ្នកណែនាំអប់រំជំនឿដោយបណ្តុះបណ្តាលអំពីព្រះបន្ទូល អំពីព្រះសហគមន៍ អំពីទេវវិទ្យានៃអគ្គសញ្ញា អំពីពិធីបុណ្យ និងអំពីសីលធម៌គ្រីស្តសាសនាជាដើម។ និងសកម្មភាពទី២ គឺការងាររបស់គណៈកម្មការព្រះគម្ពីរកាតូលិកកម្ពុជាជាអន្តរភូមិភាគ ដែលទទួលគាំទ្រពីលោកអភិបាលអន់តូនីសាមី៕

*ដោយ កល្យប្រឹក្ស*

# ព្រះសហគមន៍កាតូលិកផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ ជនរងគ្រោះដោយអគ្គីភ័យ៦៧គ្រួសារ

ជនរងគ្រោះដោយសារអគ្គីភ័យចំនួន ៦៧គ្រួសារ បានទទួលអំណោយពីព្រះ សហគមន៍កាតូលិសន្តយ៉ូសែប ផ្សារតូច នៃ ភូមភាគភ្នំពេញ នាព្រឹកថ្ងៃទី១២ កក្កដា ២០១៨ នៅសាលាសង្កាត់ឫស្សីកែវ ក្នុង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយមាន អ្នកស្រី អាន ផល្លា តំណាងអាជ្ញាធរ ខណ្ឌ និងជាតំណាងកាកបាតក្រហមកម្ពុជា សាខាខណ្ឌឫស្សីកែវចូលរួមផងដែរ។

អ្នកស្រី ផល្លា បានលើកទឹកចិត្ត ជនរងគ្រោះទាំងអស់ក្នុងនាមជាអាជ្ញាធរ គឺ"សូមបងប្អូនថែរក្សាសុខភាព និងចេះ ជួយគ្នានៅពេលមានអាសន្ន"។ ជាពិសេស អ្នកស្រីបើកចំហរ និងសហការណ៍ជា មួយសប្បុរានានា ដែលមានមានបំណង ជួយដល់ជនរងគ្រោះ។

លោកប៉ូល រឿង ផ័ត្រសិរី ជាបូជាចារ្យ ទទួលខុសត្រូវមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញខាងជើង បាននាំ នូវប្រសាសន៍ ផ្តាំសួរសុខទុក្ខបងប្អូន ពី សំណាក់លោកអូលីវីយេ អភិបាលនៃព្រះ សហគមន៍កាតូលិកភូមិភាគភ្នំពេញ។ លោក អភិបាលក៏បានផ្តាំផ្ញើតាមរយៈលោកពុក ថា "សូមឲ្យបងប្អូនមានកម្លាំងតស៊ូដើម្បី កសាងក្រុមគ្រួសារនិងសង្គមសាជាថ្មី"។ លោកបូជាចារ្យបន្តថា ក្នុងនាមព្រះសហគមន៍កាតូលិក សូមលើកទឹកចិត្តបងប្អូន សូមកុំអស់សង្ឃឹម ព្រោះរាល់ថ្ងៃមានទាំង អាជ្ញាធរដែនដី និងបងប្អូនឯទៀតៗនឹក ដល់បងប្អូន។

តំណាងអាជ្ញាធរនៃសង្កាត់ឫស្សីកែវ ដោយជួសមុខឲ្យជនរងគ្រោះទាំងអស់បាន ថ្លែងអំណរគុណដល់សប្បុរសជនទាំងអស់ ដែលបានជួយ និងបានចូលរួមរំលែកទុក្ខ និងសូមឲ្យប្រឹងប្រែងកសាងពីបាតដៃទទេ ដោយមានអាជ្ញាធរដែលតែងតែនៅជិត នឹងបងប្អូនជានិច្ច។

បើតាមប្រសាសន៍របស់លោកបូជាចារ្យ ផ័ត្រសិរី បានឲ្យដឹងថាអំណោយជាគ្រឿង ឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់ចែក ជូន ប្រជាជនក្នុងពេលនេះគឺបានមកពីការ គាំទ្រ ពីសំណាក់លោកអភិបាលអូលីវីយេ និងសប្បុរសជននៃក្រុមផ្សេងៗ។ លោក បន្តថា ព្រះសហគមន៍នឹងបន្តជួយតទៅ មុខទៀតព្រោះមើលឃើញថា គ្រួសារទាំង ៦៧នេះមិនទាន់មានគ្រឿងសម្រាប់ឧបភោគគ្រប់គ្រាន់នៅឡើយទេ ដូចជាចាន ឆ្នាំងជាដើម។ លោកបូជាចារ្យផ័ត្រសិរី បញ្ជាក់ដែរថា ព្រះសហគមន៍កាតូលិកមិន ត្រឹមតែជួយទៅលើតម្រូវការផ្លូវកាយទេ ថែម ទាំងគិតដល់តម្រូវការខាងផ្លូវវិញ្ញាណដែរ។

ប្រជាពលរដ្ឋចំនួន៦៧គ្រួសារនេះ បាន រងគ្រោះដោយអគ្គីភ័យ ដែលបានលេប ត្របាក់ផ្ទះអស់៦៤ខ្នង រួមទាំងទ្រព្យ សម្បត្តិត្រូវវិនាសទាំងស្រុង នាព្រលឹម ថ្ងៃទី១០ កក្កដា នៅភូមិមិត្តភាព សង្កាត់ ឫស្សីកែវ រាជធានីភ្នំពេញ។ អំណោយ ដែលជនរងគ្រោះទទួលពេលនោះមានដូច ជា អង្ករ១០០គីឡូក្រាមក្នុងមួយគ្រួសារ ទឹកត្រី ទឹកស៊ីអ៊ីវ មី ត្រីខ ទឹកសុទ្ធ ភួយ កន្ទេល និងតង់ជាដើម៕ *ដោយ ដាលីស*



ថតដោយ : លីហៀង

# លោកអភិបាល សូមឲ្យគ្រីស្តបរិស័ទរួមគ្នាកុំច្រណែនគ្នា



ថតដោយ : លី សុវណ្ណា

កាលពីថ្ងៃទី២ កក្កដាកន្លងទៅ ព្រះ សហគមន៍កាតូលិកភូមិភាគបាត់ដំបងបាន រៀបចំកម្មវិធី រំលឹកខួបជាអភិបាល១៨ ឆ្នាំរបស់លោកអេនរីគេ ហ្វីការេដូ និងខួប ២៣ឆ្នាំ ជាបូជាចារ្យរបស់លោកសិលា ទម្លាប់ សុផល នៅព្រះវិហារព្រះជាម្ចាស់ លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្នុង ខេត្តបាត់ដំបង ដោយមានលោកបូជាចារ្យ និងគ្រីស្តបរិស័ទមកពីព្រះសហគមន៍នានា ក្នុងភូមិភាគបាត់ដំបងយ៉ាងច្រើនកុះករ។

ក្នុងឱកាសនោះលោកអភិបាលបាន អរព្រះគុណព្រះជាម្ចាស់ដែលបានឲ្យលោក និងលោកបូជាចារ្យសុផលបានបំពេញកិច្ចការងារ នៅក្នុងព្រះសហគមន៍នៅក្នុង ប្រទេសកម្ពុជា។ ក្នុងនោះដែរលោកអភិបាលសូមរំលឹកឲ្យគ្រីស្តបរិស័ទដែលរស់ នៅក្នុងព្រះសហគមន៍គឺត្រូវចេះរួបរួមគ្នា សាមគ្គីគ្នា និងអធិដ្ឋាន។

លោកអភិបាលអេនរីគេមានប្រសាសន៍ ថា "សូមឲ្យយើងជាគ្រីស្តបរិស័ទកុំមានចិត្ត ច្រណែនគ្នា។ បើយើងច្រណែនយើងអត់ មានពេលស្រឡាញ់ បើយើងច្រណែន យើង អត់មានពេលដើម្បីទៅខាងមុខ"។ លោក អភិបាលបន្ថែមទៀតថា ក្នុងនាមជាគ្រីស្តបរិស័ទត្រូវតែស្តាប់ព្រះបន្ទូល មានជំនឿ និងសង្ឃឹមជឿជាក់ ដូចលោកយ៉ៃរ៉ូសនៅ ក្នុងគម្ពីរ ដែលទូលសុំព្រះយេស៊ូដើម្បីឲ្យ កូនរបស់គាត់រស់ឡើងវិញ។

លោកអភិបាលបន្តថា អស់អ្នកដែល ចង់ដើរតាមព្រះយេស៊ូ គឺត្រូវលះបង់ខ្លួន ឯងចោល ដូចលោកសុផល និងរូបគាត់ ផ្ទាល់។ លោកអភិបាលសង្កត់ធ្ងន់ថា អ្វី ដែលយើងលះបង់សម្រាប់ព្រះជាម្ចាស់ គឺ ព្រះអង្គនឹងប្រទានឲ្យយើងមកវិញនូវអំណរ សប្បាយ មានជីវិតដ៏ពេញលេញ។

លោកអភិបាលអេនរីគេ ហ្វីការេដូ ត្រូវ បានជ្រើសតាំងជាលោកអភិបាលដោយ សន្តអាសនៈក្នុងឆ្នាំ២០០០ ដោយមានមុខ ងារជាអ្នកមើលថែរក្សា និងគ្រប់គ្រងព្រះ សហគមន៍កាតូលិកភូមិភាគបាត់ដំបង។ លោកជាជនជាតិអេស្ប៉ាញ ជាបព្វជិតក្នុង ក្រុមគ្រួសារសហជីវិនៃព្រះយេស៊ូ ដោយ ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុង ឆ្នាំ១៩៩២។ លោកធ្លាប់បានបម្រើប្រជាជន ខ្មែរនៅក្នុងជំរំជនភៀសខ្លួនតាមព្រំដែន កម្ពុជា ថៃ។ ហើយលោកបានបន្តចូលមក បម្រើការងារនៅក្នុងប្រទេសកម្ពុជាពេល ប្រជាជនធ្វើមាតុភូមិនិវត្តន៍មកវិញនាដើ មទសវត្សទី៩០។ លោកបានបំពេញ ការងារជាមួយជនក្រីក្រ ជនពិការ ដោយ សារគ្រាប់មីន ។ល។ ក្នុងមុខងារជាអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោកបានខិតខំណែនាំគ្រីស្តបរិស័ទ បម្រើ អ្នកក្រីក្រ ជនពិការ ... ប្រកបដោយ ចិត្ត សុភាពរាបសារ និងមេត្តាករុណាតាមព្រះ ហឫទ័យព្រះជាម្ចាស់។

រីឯលោកបូជាចារ្យសិលា ទម្លាប់ សុផល ជាគ្រីស្តបរិស័ទកាតូលិក និងជាជនជាតិ ខ្មែរដែលទទួលបានមានសញ្ជាតិកាណា ហើយបានទៅរស់នៅក្នុងប្រទេសនោះ បន្ទាប់ពីជំរំជនភៀសខ្លួននៅក្នុងប្រទេស ថៃ។ ដោយសារការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យបម្រើព្រះអង្គក្នុងមុខងារជាគង្វាល ដែលនឹងត្រូវកសាងព្រះសហគមន៍កម្ពុជា ឡើងវិញ លោកក៏បានចូលសិក្សានៅ ទេវវិទ្យាល័យនៅ ហើយត្រូវបានតែង តាំងជាបូជាចារ្យនៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៥ ជាបូជាចារ្យដំបូងគេដែលទទួល អគ្គសញ្ញាតែងតាំង ក្រោយព្រះសហគមន៍ កាតូលិកនៅកម្ពុជាបានរស់ឡើងវិញក្រោយ សង្គ្រាមស៊ីវិល។ សព្វថ្ងៃនេះ លោកកំពុង បម្រើការងារជាបូជាចារ្យក្នុងភូមិភាគបាត់ដំបង លោកបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងអប់រំគ្រីស្តបរិស័ទឲ្យមានជំនឿរឹងមាំ តាមកម្មវិធីអប់រំជំនឿរបស់ព្រះសហគមន៍ កាតូលិក៕

# សារតាមបណ្តាញសង្គមប៉ុន្មានឃ្លាររបស់សម្តេចប៉ាប

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ គឺជាសកម្មជនដែលនិយមប្រើប្រាស់បណ្តាញសង្គមមួយដ៏សកម្មហើយជាពិសេសគឺនៅលើបណ្តាញ ធ្វីតធ័រ។

នៅក្នុងរយៈពេលពី៣ទៅ ៤ ថ្ងៃចុងក្រោយនេះ សម្តេចប៉ាបបានចែករំលែកនូវសារមួយចំនួន ដែលសារទាំងនោះសុទ្ធតែមានអ្នកគាំទ្រ និងចូលចិត្តរាប់ពាន់នាក់។

សារទាំងនោះ ត្រូវបានគេដឹងថា សម្តេចប៉ាបបានលើកឡើងនូវបញ្ហាមួយចំនួន នៅអឺរ៉ុប គឺមានដូចជា អឺរ៉ុបរកឃើញសេចក្តីសង្ឃឹមនៅ អំពីមជ្ឈឹមបូព៌ា អំពីគ្រីស្តបរិស័ទជាដើម។ ប្រភពដដែលបានបន្តថា សម្តេចប៉ាប លោកបានធ្វីតថា នៅពេលដែលអឺរ៉ុបរកឃើញនូវក្តីសង្ឃឹម នៅពេលនោះ មនុស្សជាតិម្នាក់ៗ គឺនៅក្នុងបេះដូងនៃស្ថាប័នរបស់ពួកគេនីមួយៗអស់ទៅហើយ ។

សម្តេចប៉ាបបានលើកឡើងថា នេះមិនមែនជាសាររបស់សម្តេចប៉ាបទេ តែជាការអធិដ្ឋានរបស់សន្តបេណេឌិកអធិដ្ឋានសម្រាប់គ្រីស្តបរិស័ទ ។

សម្តេចប៉ាបក៏បានធ្វីតបង្ហាញអំពីសមាណចិត្តជាមួយនឹងក្រុមការងារ សាម៉ារីតាន ផងដែរ ។ ដោយសម្តេចប៉ាបបានលើកឡើងថា អ្នកគឺទំនងដូចជា សាម៉ារីតានដ៏ល្អ នៅពេលអ្នកទទួលស្គាល់មុខរបស់ព្រះគ្រីស្ត ដែលនៅជិតនឹងអ្នកបំផុត ។

នៅក្នុងសារដែលសម្តេចប៉ាបបានធ្វីត ក៏បានលើកទឹកចិត្តគ្រីស្តបរិស័ទ ឲ្យចែករំលែកនូវសាររបស់ព្រះគ្រីស្ត។

ទាក់ទិននឹងនៅតំបន់មជ្ឈឹមបូព៌ា សម្តេចប៉ាបបានធ្វីតធ័រថា អ្នកទាំងអស់គ្នាអាចនឹងឮសម្រែករបស់មនុស្សជាតិជាពិសេសគឺសម្រែកនៃកុមារនៅតំបន់មជ្ឈឹមបូព៌ាដែលកំពុងតែ ជីកកប់ទឹកភ្នែករបស់ពួកគេ នៅក្នុងពិភពលោក៕

# សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ចូលរួមក្នុងពិធីមង្គលការកងអង្គរក្ស

អង្គរក្សជាតិស្វីសនិង ភរិយាជាតិប្រេស៊ីលមានការភ្ញាក់ផ្អើលនៅពេលឃើញវត្តមានរបស់សម្តេចប៉ាបក្នុងពិធីអគ្គសញ្ញាអាពាហ៍ពិពាហ៍របស់ខ្លួន។

សម្តេចប៉ាបបានបង្ហាញខ្លួននៅក្នុងពិធីអាពាហ៍ពិពាហ៍កងអង្គរក្សរបស់ព្រះអង្គជាជនជាតិស្វីស និងភរិយាដែលជាជនជាតិ ប្រេស៊ីល កាលពីថ្ងៃសៅរ៍កន្លងទៅ នេះបើតាមការចុះផ្សាយរបស់សារព័ត៌មានរបស់ប៉ុរីវ៉ាទីកង់។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានបង្ហាញខ្លួន ពេលដែលប្រកាសចាប់ផ្តើមអភិបូជា នៃអគ្គសញ្ញាអាពាហ៍ពិពាហ៍។ វត្តមានរបស់ព្រះអង្គនាំឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ លោកបូជាចារ្យ រេណាតូ ដូស សាន់តូ ជាតិប្រេស៊ីល និងជាអធិបតីក្នុងពិធីនេះមានប្រសាសន៍ថា គូស្រករទាំងពីរនេះ មិនបានដឹងថា សម្តេចប៉ាបយាងមកទេ។ លោកបន្តថា ពេលកំពុងប្រកាសស្រាប់តែបែរទៅខាងក្រោយសម្តេចប៉ាប លោកយាងគង់នៅកៅអីនោះហើយ។ លោកបន្តថា "ខ្ញុំមិនដែលជួបប្រទះទេ ក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំមិនដែលគិតថា សម្តេចប៉ាបលោកយាងមកចូលរួមកក្នុងអភិបូជាបែបនេះទេ"។ លោកថាគ្រប់គ្នាក្នុងព្រះវិហារមានការសង្ស័យ ថាតើជាសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ មែនឬយ៉ាងណា? ខ្ញុំឃើញលោកស្លៀកពាក់ជាបូជាចារ្យធម្មតាក្នុងពិធី។ លោកជាបូជាចារ្យដែលថែរក្សាកូនចៀមរបស់លោកយ៉ាងពិតប្រាកដ។ លោកឪពុក សាន់តូបន្តថា "សម្តេចប៉ាបលោកតែងប្រព្រឹត្តបែបនេះ"។

ក្នុងធម្មទេសនាសម្តេច មានប្រសាសន៍ពាក្យបីមាត់សំខាន់ "ចាប់ផ្តើម" "ឈប់" និង"បន្តដំណើរទៅមុខទៀត" ដែលលោកបានពន្យល់ថា ទាំងបីនេះចាំបាច់ណាស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍ឲ្យបានពេញលេញ។ លោកឪពុកសាន់តូបន្តថា សម្តេចប៉ាបបានសង្កត់ធ្ងន់ថា សេចក្តីស្រលាញ់ដ៏ធំធេងនៅក្នុងអគ្គសញ្ញានេះគឺ ជួយឲ្យចាប់ផ្តើមគ្រួសារមួយដែលមានវត្តមានរបស់ព្រះជាម្ចាស់នៅកណ្តាលជានិច្ច៕

# ព្រះមហាក្សត្រកម្ពុជាផ្ញើសាររំលែកទុកជូនព្រះចៅអធិរាជជប៉ុន

នាវេលាថ្ងៃព្រហស្បតិ៍ ទី១២ ខែកក្កដា ឆ្នាំ២០១៧ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជាមួយព្រះរាជវង្សានុវង្ស ព្រមទាំងប្រជានុរាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជាបាន ថ្វាយព្រះរាជសារចូលរួមរំលែកទុក្ខ និងចូលរួមសោកស្តាយជាមួយព្រះចៅអធិរាជ AKIHITO នៃព្រះរាជាណាចក្រជប៉ុន នៃការស្លាប់បាត់បង់ជីវិតជាច្រើនរយនាក់ និងបាត់ខ្លួនជាច្រើននាក់ របស់ជាប្រជាពលរដ្ឋជប៉ុន ក្នុងគ្រោះធម្មជាតិភ្លៀងធ្លាក់យ៉ាងខ្លាំងដែលបង្កឲ្យក្លាយជាទឹកជំនន់ និងបាក់ដីយ៉ាងធ្ងន់ធ្ងរ នៅប៉ែកខាងត្បូង និងខាងលិចប្រទេសជប៉ុន តាំងពីចុងសប្តាហ៍មុន។

ក្រៅពីព្រះមហាក្សត្រ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្ញើសាររំលែកទុក្ខជូនសមភាគី និងប្រជាជនជប៉ុនចំពោះគ្រោះមហន្តរាយធម្មជាតិនេះផងដែរ។

សម្តេចតេជោ ហ៊ុន សែន បាន សរសេរលិខិតជូនលោក ហ្ស៊ីនហ្សូ អាបេ នាយករដ្ឋមន្ត្រីជប៉ុនថា "ខ្ញុំមានអារម្មណ៍សោកស្តាយជាអនេកពន់ពេកនៅពេលទទួលព័ត៌មានពីការបាត់បង់ជីវិតមនុស្សជាច្រើនក្នុងគ្រោះទឹកជំនន់ និងបាក់ដីដោយសារភ្លៀងធ្លាក់ខ្លាំង ដែលបានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរ នៅប៉ែកខាងត្បូង និងខាងលិចប្រទេសជប៉ុន តាំងពីចុងសប្តាហ៍មុន។ តាងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ខ្ញុំសូមសម្តែងនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុតចំពោះ ឯកឧត្តម ស៊ីនហ្សូ អាបេ នាយករដ្ឋមន្ត្រីជប៉ុន និងប្រជាជនជប៉ុន ពិសេសគ្រួសារនៃសពក្នុងគ្រាទុក្ខសោកដោយការបាត់បង់ដ៏ធំធេងនេះ។

ក្រៅពីមេដឹកនាំ នៅលើបណ្តាញសង្គម ក៏មានប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់ផ្សេងទៀត បានផ្ញើសាររំលែកទុក្ខជូនប្រជាជនជប៉ុន ដែលកំពុងតែរងគ្រោះដោយសារតែទឹកជំនន់នេះផងដែរ៕

# រោងចក្រគីមីមួយកន្លែងនៅចិនផ្ទុះសម្លាប់មនុស្សជិត២០នាក់

រោងចក្រគីមីមួយកន្លែងនៅខេត្តស៊ីឈ័នប្រទេសចិនបានផ្ទុះដោយសម្លាប់មនុស្សប្រមាណជា ជិត២០ នាក់ ។

បណ្តាញព័ត៌មានចិនបានរាយការណ៍ថា ហេតុការណ៍នេះគេរកឃើញមនុស្ស ១៩នាក់ស្លាប់និង១២នាក់ផ្សេងទៀតរងរបួស។

អាជ្ញាធរក្នុងខណ្ឌជៀនអាន នៅក្នុងខេត្តស៊ី ឈ័ន បាននិយាយក្នុងសេចក្តីថ្លែងការណ៍មួយថា គេនៅមិនទាន់ដឹងច្បាស់អ្វីបង្កការផ្ទុះកាលពីថ្ងៃព្រហស្បតិ៍នៅរោងចក្រយីប៊ិន ហេងដា នោះទេ។

រូបភាពក្នុងបណ្តាញសង្គមចិនបានបង្ហាញអគ្គិភ័យខ្លាំងមួយដោយមានកំសួលផ្សែងហុយចេញពីរោងចក្រដ៏សន្ធោសន្ធៅ។

ចិនបានចាប់ផ្តើមវិធានការធ្វើអោយប្រសើរឡើងសុវត្ថិភាពឧស្សាហកម្ម ដោយបង្កើនការត្រួតពិនិត្យនៅរយៈពេលមួយឆ្នាំមកនេះ ក្រោយឧបទ្ទវហេតុនៅអណ្តូងរ៉ែធ្យូងថ្មនិងរោងចក្រគីមី។

នៅឆ្នាំ២០១៥ ការផ្ទុះមួយនៅឃ្លាំងស្តុកសារធាតុគីមីមួយនៅក្នុងក្រុងទៀនជីនបានសម្លាប់មនុស្ស១៦៥នាក់។ កាលពីឆ្នាំមុន ការផ្ទុះមួយនៅរោងចក្រគីមីនៅខេត្តសាទុងសម្លាប់មនុស្ស៨នាក់៕



# មនុស្សក្រៅភព និង អ្វីដែលអ្នកវិទ្យាសាស្ត្រនិយាយអំពីពួកគេ

អ្នករូបវិទ្យា តារាសាស្ត្រ អ្នកជីវសាស្ត្រក្រៅភពក៏ដូចជា អ្នកសិក្សាអំពីឆ្អឹងមនុស្សសត្វ សុទ្ធសឹងតែជាអ្នកដែលចាប់អារម្មណ៍អំពីមនុស្សក្រៅភពផែនដី ឬគេហៅថាអេលៀន។នៅពេលនេះ យើងអាចស្ដាប់និងមើលនូវអ្វីដែលអ្នកវិទ្យាសាស្ត្រនិយាយអំពីលទ្ធភាពនៃជីវិតនៅក្រៅភពផែនដី ស្របពេលនឹងទិវាពិភពលោកស្ដីអំពីយានក្រៅភព កាលពីថ្ងៃទី២ ខែកក្កដា។

តើមនុស្សនៅតែឯងនៅក្នុងចក្រវាលដ៏ធំធេងនេះឬ? នេះគឺសំណួរដែលធ្វើឲ្យវិលមុខ ហើយនឹងត្រូវបានចោទសួរឡើងវិញ នៅរាល់ពេលរបកគំហើញថ្មីៗនីមួយៗនៃភពដែលនៅសែនឆ្ងាយហើយដែលគេគិតថាងាយស្រួលនឹងផ្ដល់ជម្រកដល់ភាវរស់មានជីវិត។

ដោយឡែក របកគំហើញនៃភពប្រូស៊ីម៉ាប៊ីដែលជាពិភពលោកដែលមានសក្ដានុពលខ្ពស់ក្នុងការផ្ដល់ទីជម្រក ដែលនៅជិតបំផុត និងមិនដែលត្រូវបានគេរកឃើញពីមុន ធ្វើឲ្យសើបសាជាថ្មីសម្រាប់ការស្រមើស្រមៃរបស់មនុស្សជាតិក្នុងការស្វែងរកមនុស្សក្រៅភព។ ប៉ុន្តែតើវាមានភាពសមហេតុផលដែរឬទេ? ដែលសង្ឃឹមថា នឹងរកឃើញនូវថ្ងៃណាមួយនូវទម្រង់ជីវិតក្រៅភពផែនដីនៅកន្លែងណាមួយនៅក្នុងចក្រវាលនេះ? អ្នកខ្លះជឿថា វាសមហេតុផល។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ អ្នករូបវិទ្យាតារាសាស្ត្រដ៏ល្បីល្បាញ ស្ទេហ្វិនហកឃីង បានប្រកាសអំពីមូលនិធិ "ប្រេកស្រ៊ូ លីស្ទេន" ដើម្បីបង្កើតប្រអប់ដ៏រឹងមាំនៃថវិកា ដែលមានប្រមាណ ៩២លានអឺរ៉ូ។ គំនិតផ្ដួចផ្ដើមនេះមានគោលដៅខុសពីធម្មតា គឺបំបែកសំបុកនៅក្នុងជម្រៅនៃផ្ទៃមេឃ ដើម្បីស្វែងរកសញ្ញានៃបញ្ញាញាណភាវរស់នៅក្រៅភពផែនដី។ ប្រព័ន្ធផ្សព្វផ្សាយវិទ្យាសាស្ត្រអង់គ្លេសនៃសង្គមរាជានៅទីក្រុងឡុង បានប្រកាសថា ៖ "វាគ្មានសំណួរណា ដែលធំជាងនេះទៀតនោះទេ"។ នៅឱកាសនេះ យើងសូមស្នើអ្នកឲ្យស្វែងរកសាជាថ្មីម្ដងទៀតនូវអ្វី ដែលអ្នកវិទ្យាសាស្ត្រផ្សេងៗគ្នា បាននិយាយអំពីលទ្ធភាពនៃជីវិតនៅក្រៅភពផែនដី។ សម្មិតកម្មដែលគួរឲ្យភ្ញាក់ផ្អើល គឺបានមានភាពសកម្មម្ដងទៀត កាលពីខែតុលា ឆ្នាំ២០១៥ ដោយសារការឃើញពន្លឺរញ៉េរញ៉ៃចំឡែកនៃផ្កាយដែលហៅថា KIC 84.62.852 ដែលស្ថិតនៅចម្ងាយ ១៤៨០ ឆ្នាំពន្លឺពីផែនដី...។

នៅខែសីហា ឆ្នាំ២០១៣ អ្នកជីវសាស្ត្រក្រៅភព នៃមជ្ឈមណ្ឌលជាតិនៃការសិក្សាអវកាស បារាំងបានលើកសំណួរដែលធ្វើឲ្យរំភើបដល់គ្រប់អ្នកប្រមាញ់ភាវរស់ក្រៅភពទាំងអស់ គឺថា តើអ្វីជាធាតុចាំបាច់សម្រាប់ការលេចឡើងនូវជីវិត? តើគីមីនៃជីវិតឆ្លងកាត់យ៉ាងដូចម្ដេច? ប្រសិនបើមានជីវិតនៅលើភពព្រះអង្គារ តើយានគៀរីយ៉ូស៊ីធីដែលធ្វើដំណើរដ៏វែងឆ្ងាយនៅលើភពក្រហមតាំងពីរដូវក្ដៅ ២០១២ នឹងអាចរកជីវិតឃើញនៅក្នុងទម្រង់ជាអ្វី?

ដោយសារតែភពអង្គារដែលជាបងប្អូនជាមួយផែនដី មានលក្ខណៈល្អ និងអាចផ្ដល់ជម្រកដល់ភាវរស់មានជីវិត វាក៏ដូចជាគ្នានឹងសម្មិតកម្ម ដែលមានភាពប្រហាក់ប្រហែលបំផុត ដូចដែលត្រូវបានពន្យល់អំពីភពនេះ កាលពីខែតុលា ឆ្នាំ២០១៤ ដោយក្រុមអន្តរជាតិនៃអ្នកសិក្សាស្រាវជ្រាវ។ ពួកគេបានធ្វើការវិភាគសន្ទស្សន៍ដែលត្រូវដកចេញពីដុំអាចម៍ផ្កាយភពព្រះអង្គារ។ ប៉ុន្តែតើវាស្ថិតនៅក្រោមទម្រង់ជាអ្វី ជីវិតនៅភពព្រះអង្គារនេះ?

សម្រាប់ការពន្យល់នៅឆ្នាំ ២០០៧ លោក អង់ ដ្រេ ប្រាក អ្នកជីវសាស្ត្រក្រៅភព ជនជាតិបារាំង បាននិយាយថា ៖ "ខ្ញុំមិនគិតថា ក្នុងនាមជា អូម៉ូសាព្យាង ឬមនុស្សសម័យ យើងនៅឯកោនៅក្នុងចក្រវាល ក៏ប៉ុន្តែវាប្រហាក់ប្រហែលថា ជីវិតអាចនឹងមានវត្តមាននៅទីកន្លែងផ្សេងៗទៀតនៅក្នុងចក្រវាល ប៉ុន្តែនៅក្រោមទម្រង់ជាបាក់តេរី"។ ដោយបង្ហាញនូវដំណោះស្រាយសុទិដ្ឋិនិយម រូបវិទូតារាសាស្ត្រ មីសែល ម៉ែយឺ បានអធិប្បាយថា ៖ "វាគ្មានការសង្ស័យណាមួយនោះឡើយ បើមានលក្ខខណ្ឌដែលចាំបាច់ ក៏មានការលេចឡើងនូវជីវិត នៅទីកន្លែងដទៃទៀតនៅក្នុងចក្រវាលដ៏ធំធេងនេះផងដែរ"។

សំណួរមួយទៀតដែលត្រូវបានគេចោទសួរផងដែរគឺថា មនុស្សជាតិនឹងមានប្រតិកម្មដូចម្ដេចប្រសិនបើមានភាវរស់ក្រៅភពពិតប្រាកដនៅលើសារព័ត៌មាន។ តើមនុស្សជាតិនឹងចលាចល ភ័យខ្លាច ឬសង្ស័យ? ឬក៏ផ្ទុយមកវិញ មានសេចក្ដីសង្ឃឹមរីករាយ និងសុទិដ្ឋិនិយម។ លោកសាស្ត្រាចារ្យចិត្តវិទ្យាជនជាតិអាម៉េរិកាំងលោក ម៉ៃឃើល វ៉ារនុម អ្នកសិក្សាស្រាវជ្រាវនៅសកលវិទ្យាល័យរដ្ឋនៃតំបន់អារីសូណា សហរដ្ឋអាម៉េរិក បានព្យាយាមឆ្លើយនឹងសំណួរនេះ។ ដោយការសិក្សាស្រាវជ្រាវបានបង្ហាញថា ប្រតិកម្មរបស់មនុស្សជាតិទៅនឹងការប្រកាសអំពីភាពដែលអាចទៅរួចនៃជីវិតនៅក្រៅភពផែនដីគឺវិជ្ជមានជាទូទៅ។

លោកម៉ៃឃើល វ៉ារនុម បានសន្និដ្ឋានថា ៖ "ប្រសិនបើថ្ងៃណាមួយ មនុស្សជាតិដឹងថា យើងមិនមែននៅតែម្នាក់ឯងនៅក្នុងចក្រវាលនេះ យើងនឹងមានអារម្មណ៍ល្អជាងនេះ វៀរលែងតែថា ទម្រង់ជីវិតក្រៅភព បានលេចឡើងក្នុងរបៀបជាហ្វូងយានអវកាសចម្បាំងដែលប្រុងប្រៀបកំទេចពិភពលោក។"

ជាចុងក្រោយលោកសាស្ត្រាចារ្យរូបវិទូតារាសាស្ត្រ អង់គ្លេស លោក ស្ទេហ្វិន ហ៉កឃីង ធ្លាប់បាននិយាយថា ៖ "នៅពេលខ្ញុំកាន់តែចាស់ ខ្ញុំកាន់តែយល់ច្បាស់ថា មនុស្សជាតិមិនមែននៅតែឯងនៅក្នុងចក្រវាលនេះទេ។ បន្ទាប់ពីមួយជីវិតក្នុងការពិចារណា ខ្ញុំក៏ចូលជួយដឹកនាំនៅក្នុងការខិតខំប្រឹងប្រែងថ្មីមួយ ជាលក្ខណៈសកលដើម្បីស្វែងរកជីវិតក្រៅភព"៕ *ដោយ ផាត សំភី*



ថតដោយ : អ៊ីនធឺណែត

# រូបភាពព្រះសហគមន៍ប្រចាំខែ



មជ្ឈមណ្ឌលកុមារកំព្រា គៀនឃ្លាំង
រូបភាព៖ លីហៀង



ពិធីចែកវិញ្ញាបនបត្ររបស់សិស្សសាលាអប់រំជំនឿសន្តយ៉ូស្វីន។ រូបភាព៖ សុធីរិទ្ធ



ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ បានទទួលបងប្អូន១៥នាក់ចូលក្នុងព្រះសហគមន៍ (ទទួលជំហានទី១ នៃអគ្គសញ្ញាជ្រមុជទឹក)។ រូបភាព៖ ឫទ្ធីរដ្ឋ



អធិដ្ឋានពេញយប់សម្រាប់ការត្រាស់ហៅ នៅអារាមកាម៉ែល។
រូបភាព៖ លី សុវណ្ណា


Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវីរីតាស់អាស៊ីខេមរភាសា

### សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវីរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយ៍វិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្ដាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com, www.catholiccambodia.org

-លោកអ្នក ក៏អាច Follow face book ផ្លូវការរបស់យើង https://www.facebook.com/RVAKHMER/

**✥ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវីរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Varitas Asia
Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com